# ដំណោះស្រាយ

## សំនួរសិក្សាទី ១

ចូរអានសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៧៨៩) ។
តើមាត្រាណាខ្លះនៃសេចក្តីថ្លែងការណ៍នេះចង្អុលពី "ការនិយាយស្តីដោយសេរី"?

មាត្រា១១ នៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស (១៧៨៩)

## សំនួរសិក្សាទី ២

មេដឹកនាំអាស៊ីមួយចំនួន (ឧទាហរណ៍ដូចជានៅប្រទេសសឹង្ហបុរី និងម៉ាឡេស៊ី) អះអាងថា "តំលៃរបស់អាស៊ី" (= វិញ្ញាណនៃការគោរពអាជ្ញាធរ និង ជឿថា ក្រុម គឺមានសារៈសំខាន់ជាងបុគ្គល) លើសពីសិទ្ធិមមនុស្ស ។ ពួកគេនិយាយថា ពួកគេអាចទទួលបានសេរីភាពសេដ្ឋកិច្ច (ដូចជាសេរីភាពក្នុងការកាន់កាប់ និងសេរីភាពក្នុងការប្រកបវិជ្ជាជីវៈ) ប៉ុន្តែ មិនត្រូវទទួលបានសេរីភាពបុគ្គលនោះទេ (ដូចជាសេរីភាពក្នុងការនិយាយស្តី) នៅពេលតែមួយនោះទេ ព្រោះថាសេរីភាពបុគ្គលទាំងនេះជាឧបសគ្គសំរាប់ការត្រួតពិនិត្យរបស់រដ្ឋ និងការលូតលាស់ផ្នែកសេដ្ឋកិច្ច ។

តើអ្នកយល់ស្រប ឬ មិនយល់ស្របនឹងយោបល់នេះ? សូមពន្យល់អំពីគំនិតរបស់អ្នក ។

ដោយសារ សិទ្ធិមនុស្សមិនត្រឹមតែមានលក្ខណៈជាប់ពីកំណើតនៃបុគ្គលម្នាក់ៗ និងមិនអាចលក់ ឬផ្ទេរបានទេ ថែមទាំងមិនអាចចែករំលែកបាន និងមានលក្ខណៈជាសកលទៀតផង ដូច្នេះការអះអាងថា តំលៃរបស់អាស៊ីលើសពីសិទ្ធិមនុស្សនោះគឺមិនត្រឹមត្រូវទេ ។

## សំនួរសិក្សាទី ៣

សូមអានកតិកាសញ្ញា និងសេចក្តីប្រកាសនានា ដែលហៅថា "កំរងសិទ្ធិអន្តរជាតិ"(International Bill of Rights) ។

តើមាត្រាណាខ្លះដែលទាក់ទងនឹង "សិទ្ធិបោះឆ្នោត"?

មាត្រា២១ UDHR
មាត្រា២៥ ខ ICCPR



## ករណីសិក្សាទី ១

ហ្វូងមនុស្សដែលខឹងសម្បា បានសំលាប់ចោរនៅលើដងផ្លូវនៅក្នុងទីក្រុងភ្នំពេញ ។ ពួកគេកំពុងសើច ។

ក. ចូរសាកល្បងពិចារណាអំពីអ្វីដែលពួកគេគិត និងមានអារម្មណ៍ ។ ចូររៀបរាប់ពីអារម្មណ៍របស់ពួកគេ ។

ខ. ចូរសាកល្បងពិចារណាពីអ្វីដែលជនរងគ្រោះមានអារម្មណ៍ និងបានគិត ។ បើសិនជាអ្នកស្ថិតក្នុងស្ថានភាពជាជនរងគ្រោះវិញ តើអ្នកគួរនិយាយអ្វីដើម្បីការពារខ្លួន ?

គ. ចូរសាកល្បងពិចារណាពីអ្វីដែលម្ចាស់ហាងមានអារម្មណ៍ និងបានគិត បើសិនជាទ្រព្យសម្បត្តិរបស់គាត់ត្រូវបានចោរលួច ។ ចូររៀបរាប់ពីអ្វីដែលគាត់គួរតែនិយាយ ?

ចូពិភាក្សាសំនួរទាំងនេះជាមួយមិត្តភក្តិ និង/ឬ សហការីរបស់អ្នក!

## សំនួរសិក្សាទី ៤

ក. តើសិទ្ធិជាមូលដ្ឋានណាខ្លះដែលពាក់ព័ន្ធនៅក្នុងវិវាទរវាង ម្ចាស់ហាង ចោរ និងហ្វូងមនុស្សដែលសំលាប់ចោរនេះ?

ម្ចាស់ហាង: សិទ្ធិលើកម្មសិទ្ធិ ( មាត្រា៤៤ II CC)
សិទ្ធិដែលត្រូវទទួលបានការការពារពីប៉ូលីស ( សន្តិសុខ - មាត្រា៣២ I CC)

ចោរ: សិទ្ធិរស់រានមានជីវិត
សិទ្ធិការពារបូរណភាពរូបរាងកាយ ( មាត្រា៣៨ I , II CC)
សិទ្ធិមិនត្រូវបានទទួលរងនូវទារុណកម្ម ( មាត្រា៣៨ III CC)
សិទ្ធិមិនត្រូវបានដាក់ទោសប្រហារជីវិត ( មាត្រា៣២ II CC)

ហ្វូងមនុស្ស: សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី ( មាត្រា៤១ I ១ CC) ប៉ុន្តែពុំមានសិទ្ធិសំលាប់ទេ ។

ខ. តើអ្វីទៅជាហេតុផលរបស់ហ្វូងមនុស្សដែលសំលាប់ចោរ?

- ការអនុវត្តន៏ច្បាប់ដ៏ទន់ខ្សោយរបស់ប៉ូលីស និងប្រព័ន្ធតុលាការ (គ្មានការដាក់ទណ្ឌកម្មទៅលើចោរ និងទៅលើហ្វូងមនុស្សដែលសំលាប់ចោរ) ។
- គ្មានការដាក់ទោសជាសាធារណៈទៅលើហ្វូងមនុស្សដែលសំលាប់ចោរ ដោយអ្នកដឹកនាំ អ្នកនយោបាយ ឬដោយអ្នកគ្រប់គ្រង ។
- បំបាត់ចោលនូវការរសាយចិត្ត និងភាពតានតឹង ដោយការធ្វើមិនគួរគប្បីចំពោះបុគ្គលដែលមានឋានៈទាបជាងបង្កើតឱ្យមានអារម្មណ៍ល្អ ។

គ. តើវិវាទនេះត្រូវបានដោះស្រាយយ៉ាងណា?

- ការធ្វើអន្តរាគមដោយអ្នកនៅជិតហេតុការណ៍ ដោយរំដោះចោរចេញ ។
- មានការណែនាំយ៉ាងច្បាស់ពីមេប៉ូលីស ឬអគ្គព្រះរាជអាជ្ញា ដែលដាក់ទោសដល់មនុស្សដែលសំលាប់ចោរ ។
- ការបង្រៀននៃកិរិតសីលធម៌ល្អ និងច្បាប់ នៅក្នុងសាលាអំពីសិទ្ធិមនុស្សដែលសូម្បីតែចោរក៏មានដែរ ។
- វិធានការប្រឆាំងនឹងអំពើពុករលួយដើម្បីបង្ការកុំឱ្យប៉ូលីសបន្តចាប់ចោរដើម្បីលុយ តទៅទៀត ។

## សំនួរសិក្សាទី ៥

ចូរដកស្រង់នូវបទបញ្ញត្តិច្បាប់ (មាត្រា) ជាតិ និងអន្តរជាតិនានា ដែលការពារដល់សិទ្ធិស្ត្រីក្នុងការការពាររូបរាងកាយរបស់ពួកគេ ។

បទបញ្ញត្តិអន្តរជាតិ:

- មាត្រា ៥ UDHR (សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស)
- មាត្រា៧ ឃ្លាទី១ ICCPR (កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)
- មាត្រា២ ខ, គ, ឃ, ង មាត្រា៣, មាត្រា៥ I និង មាត្រា១៦ I ឃ CEDAW (អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី)
- មាត្រា ៣៤ CRC (អនុសញ្ញាស្តីពីសិទ្ធិកុមារ)
- មាត្រា២ ពាក់ព័ន្ធនឹងមាត្រា១ អនុសញ្ញាស្តីពីទាសភាព (ក្នុងករណីដែលស្ត្រីកំពុងត្រូវគេជួញដូរ)

បទបញ្ញត្តិជាតិ:

- មាត្រា៤៥ I និង ទី២ មាត្រា៤៦ I និង មាត្រា៤៨ I នៃរដ្ឋធម្មនុញ្ញកម្ពុជា
- មាត្រា ១៧២ ច្បាប់ការងារ
- មាត្រា៣៣, ៤១ និង ៤២ នៃក្រមព្រហ្មទណ្ឌអន្តរកាល
- គ្រប់មាត្រានៃច្បាប់ស្តីពីការចាប់ជំរិត ការរត់ពន្ធ និងជួញដូរមនុស្ស (មករា ១៩៩៦)
- គ្រប់មាត្រាទាំងអស់នៃសេចក្តីព្រាងច្បាប់ស្តីពីអំពើហិង្សាគ្រួសារ (ជំពូកទី១ត្រូវបានរដ្ឋសភាអនុម័តរួច សូមមើលឯកសារភ្ជាប់ជាមួយ)

## សំនួរសិក្សាទី ៦

នៅឆ្នាំ២០០២ ហាងខារ៉ាអូខេទាំងអស់ត្រូវបិទទ្វារដោយសារបទបញ្ជាមួយ និងត្រូវតែបិទក្នុងរយៈពេលខ្លីបំផុត ។

ក. តើអ្នកណាខ្លះជាភាគីដែលពាក់ព័ន្ធនៅក្នុងរឿងនេះ?

ភាគីដែលពាក់ព័ន្ធរួមមាន:

- រដ្ឋាភិបាល
- ម្ចាស់ហាងខារ៉ាអូខេ
- បុគ្គលិកធ្វើការនៅហាងខារ៉ាអូខេ
- អតិថិជនរបស់ហាងខារ៉ាអូខេ
- អ្នកជិតខាងហាងខារ៉ាអូខេដែលត្រូវសំលេងអ៊ូអររំខាន

ខ. ចូររៀបរាប់ និងពន្យល់អំពីផលប្រយោជន៍ប្រកួតប្រជែងរបស់ភាគីនីមួយៗ ។ សូមបញ្ជាក់អំពីបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធផង:

ផលប្រយោជន៍របស់រាជរដ្ឋាភិបាល:

- ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈ និង សន្តិសុខ មាត្រា៥២ ឃ្លាទី២ ជំរើសទី២ CC
- ដើម្បីលុបបំបាត់ការកេងប្រវ័ញ្ចលើស្ត្រីភេទក្នុងការងារ មាត្រា៤៥ II CC
- ដើម្បីធ្វើឱ្យលក្ខខណ្ឌរស់នៅរបស់ស្ត្រីមានភាពសមរម្យ មាត្រា៤៦ III CC

ផលប្រយោជន៍ម្ចាស់ហាង៖

- មានសិទ្ធិកម្មសិទ្ធិ មាត្រា ៤៤ I និង II CC

ផលប្រយោជន៍បុគ្គលិក៖

- សេរីភាពបុគ្គល មាត្រា៣២ ជំរើសទី២ CC
- មានសិទ្ធិជ្រើសរើសការងារដោយសេរី មាត្រា៣៦ I CC

ផលប្រយោជន៍របស់អតិថិជន៖

- ទទួលបាននូវសិទ្ធិសេរីភាពបុគ្គល មាត្រា៣២ ជំរើសទី២ CC

ផលប្រយោជន៍របស់អ្នកជិតខាង

- ទទួលបាននូវសិទ្ធិសេរីភាពបុគ្គល (ឧទាហរណ៍ ទៅគេងនៅពេលណាដែលពួកគេចង់) និង សន្តិសុខ មាត្រា៣២ ជំរើសទី២ និងទី៣ CC

គ. តើបទបញ្ជាឱ្យបិទហាងខារ៉ាអូខេទាំងអស់នោះស្របទៅនឹង "គោលការណ៍នៃភាពសមាមាត្រ" ដែរឬទេ? សូមពន្យល់អំពីយោបល់ផ្នែកច្បាប់របស់អ្នក ។

"គោលការណ៍សមាមាត្រ"ចែងថា សកម្មភាពរដ្ឋបាលអាចត្រូវអនុវត្តដោយការប្រើវិធានការទន់ភ្លន់ជាមុនសិន។ គឺមានតែវិធានការទន់ភ្លន់ទេដែលមិននាំឱ្យមានប្រតិកម្មដោយចេតនា ហើយបន្ទាប់មកវិធានការខ្លាំងជាងមុន ត្រូវបានអនុវត្ត ។ បន្តិចម្តងបន្តិចម្តង វិធានការដែលចេញពីភាពទន់ភ្លន់ទៅរកវិធានការដាច់ខាត ត្រូវបានគេធ្វើតាម ។

ការបិទហាងខារ៉ាអូខេ**ទាំងអស់នៅក្នុងរយៈពេលខ្លីបំផុត**គឺមិនមានសមាមាត្រទេ ។ ដើម្បីសម្រេចគោលបំណងរបស់រដ្ឋាភិបាលក្នុងការធានាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ (មាត្រា៥២ ឃ្លាទី២ ជំរើសទី២ CC) វាមិនចាំបាច់ត្រូវបិទហាងខារ៉ាអូខេទាំងអស់នោះទេ ព្រោះថា មិនមែនគ្រប់ហាងខារ៉ាអូខេសុទ្ធតែដំណើរការខុសច្បាប់ឡើយ (ដូចជាបនពេស្យា) ។

ប៉ុន្តែទោះជាពួកគេដំណើរការខុសច្បាប់ក៏ដោយ ក៏មិនត្រូវបិទហាងខារ៉ាអូខេទាំងនោះក្នុងរយៈពេលដ៏ខ្លីបែបនោះដែរ គឺវាមិនសមាមាត្រទេ ។ សិទ្ធិជាមូលដ្ឋានរបស់ម្ចាស់ហាងក្នុងការកាន់កាប់ (មាត្រា៤៤ I និង II CC) តំរូវឱ្យផ្តល់ពតិមានជាមុនដែលថា ម្ចាស់ហាងនឹងត្រូវផ្តល់ពេលវេលាមួយ (ឧ. ២សប្តាហ៍) ក្នុងការបិទហាងដោយខ្លួនគេផ្ទាល់ ។ គឺមានតែនៅពេលម្ចាស់ហាងដែលធ្វើដំណើរការខុសច្បាប់ មិនព្រមបិទទ្វារហាងរបស់ខ្លួនទេ ទើបរដ្ឋាភិបាលអាចប្រតិបត្តិបទបញ្ជាដោយរបស់ខ្លួនបាន (ដែលហៅថា "ប្រតិបត្តិការជំនួស") ។

## សំនួរសិក្សាទី ៧

បន្ទាប់ពីមានកុបកម្មប្រឆាំងនឹងថៃនាថ្ងៃ២៩ មករា ២០០៣ អាជ្ញាធរបាននិយាយថា "យើងមិនអាចបញ្ឈប់បាតុករដែលប្រើអំពើហិង្សាបានទេ ពីព្រោះយើងមានជំរើសតែពីរ៖ មួយឱ្យពួកគេបន្តធ្វើបាតុកម្ម ឬមួយ បាញ់ពួកគេ" ។

ចូរអានច្បាប់ស្តីពីបាតុកម្មដែលមានភ្ជាប់ជាមួយនេះ ។

តើមានជំរើសតែពីរសំរាប់អាជ្ញាធរមែនឬ?

តើមានវិធានការផ្សេងៗអ្វីខ្លះ ដែលច្បាប់ស្តីពីបាតុកម្មចែងអំពីបាតុកម្មដោយហិង្សា? (ចូរកុំភ្លេចដកស្រង់មាត្រាច្បាប់ដែលពាក់ព័ន្ធឱ្យបានច្បាស់លាស់!) ។

ចម្លើយគឺ ទេ មិនមែនមានតែជំរើសពីរ (បាញ់ ឬឱ្យពួកគេធ្វើ) នោះទេ ប៉ុន្តែមានវិធានការផ្សេងៗគ្នាជាច្រើន យោងតាមច្បាប់ស្តីពីបាតុកម្ម ។

១. អាជ្ញាធរអាចហាមបាតុកម្ម (មាត្រា៤ I នៃច្បាប់ស្តីពីបាតុកម្ម)
២. អាជ្ញាធរអាចជូនដំណឹងអំពីការហាមឃាត់ចំនួនពីរដង (មាត្រា ៤ II នៃច្បាប់ស្តីពីបាតុកម្ម)
៣. ប្រសិនបើក្រុមបាតុករនៅបន្តសកម្មភាពបាតុកម្មរបស់ខ្លួន ពួកគេអាចត្រូវបំបែកពីគ្នាដោយឧបករណ៍ដែលមិនធ្វើឱ្យគ្រោះថ្នាក់ដល់អាយុជីវិត
៤. បាតុករដែលមានអាវុធអាចត្រូវដកហូតអាចអាវុធ (មាត្រា៥ I)
៥. បាតុករដែលមិនមានអាវុធអាចត្រូវឃុំខ្លួនជាបណ្តោះអាសន្ន (មាត្រា ៥ II)
៦. បាតុកម្មហិង្សាអាចត្រូវបញ្ឈប់តាមវិធានការសមស្របជាច្រើន (មាត្រា៦ I)

## សំនួរសិក្សាទី ៨

សំណុំរឿង:

ប៉ូលីសចាប់ខ្លួនមនុស្សម្នាក់ក្នុងចំណោមបុរសជាច្រើនដែលបានរំលោភស្ត្រីម្នាក់ ។ នៅក្នុងពន្ធនាគារ ពួកគេសួរគាត់ឱ្យប្រាប់ពីឈ្មោះជនល្មើសផ្សេងទៀត ប៉ុន្តែគាត់បដិសេធមិនប្រាប់ឈ្មោះអ្នកទាំងនោះទេ ។ ប៉ូលីសវាយគាត់ជាច្រើនលើក ដើម្បីចង់ដឹងឈ្មោះមិត្តភក្តិរបស់គាត់ ។

អ្នកទោសដែលត្រូវគេវាយដំ បានទំនាក់ទំនងជាមួយមេធាវីរបស់ខ្លួន និងសុំឱ្យមេធាវីប្តឹងអំពីការធ្វើមិនគួរគប្បីរបស់អាជ្ញាធរ ។

តើបណ្តឹងរបស់គាត់ត្រឹមត្រូវដែរឬទេ?

សូមពិនិត្យសំណួរ ដោយឆ្លើយម្តងមួយៗ នូវសំណួរនីមួយៗក្នុងបញ្ជីផ្ទៀងផ្ទាត់!

**១. តើបុគ្គល និង ស្ថាប័នពាក់ព័ន្ធនឹងវិវាទនេះមានអ្វីខ្លះ?**

- មន្ត្រីពន្ធនាគារ (ប៉ូលីស)
- ជនល្មើសដែលត្រូវគេវាយ
- មេធាវី
- ពន្ធនាគារ
- តុលាការ

**២.** តើអ្វីខ្លះជា**ទំនាស់ផលប្រយោជន៍**របស់បុគ្គល និងស្ថាប័នទាំងនេះ និង តើបុគ្គល និងស្ថាប័នទាំងនេះមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?

| | |
|---|---|
| អ្នករំលោភគេដែលត្រូវគេវាយ: | គាត់មិនចង់ឱ្យគេវាយទេ |
| មន្ត្រីពន្ធនាគារ: | ពួកគេចង់បានពត៌មានពីអ្នកចាប់រំលោភស្ត្រី ទោះជាតាមមធ្យោបាយអ្វីក៏ដោយ(ទោះដោយវាយដំច្រើនលើកក៏ដោយ) អំពីជនល្មើសផ្សេងទៀតដែលបានរំលោភនារីនោះ |
| មេធាវី: | គាត់ចង់ការពារផលប្រយោជន៍របស់កូនក្តីគាត់ |
| ពន្ធនាគារ: | ឃុំជនដែលមានពិរុទ្ធ និង ជាប់ចោទ ក្នុងការឃុំខ្លួនមុនពេលជំនុំជំរះ |
| តុលាការ: | ត្រូវស្វែងរកយុត្តិធមិតាមការវិនិច្ឆ័យដោយឯករាជ្យដោយធ្វើការអនុវត្តន៏ច្បាប់ |

### ៣. សិទ្ធិ និងភារកិច្ចៈ

#### ក. តើមានសិទ្ធិអ្វីខ្លះដែលត្រូវប៉ះពាល់?

អ្នករំលោភគេដែលត្រូវគេវាយៈ

- មាត្រា៧ ឃ្លាទី១ ICCPR សិទ្ធិមិនត្រូវគេធ្វើទារុណកម្ម ឬវាយដំឃោឃៅ និងអមនុស្សធម៌ (ខចែងទូទៅសំរាប់មនុស្សគ្រប់រូប!)
- មាត្រា ១០ I ICCPR សិទ្ធិរបស់អ្នកជាប់ឃុំត្រូវគេប្រព្រឹត្តទៅលើ ដោយមនុស្សធម៌ និងគោរពសេចក្តីថ្លៃថ្នូរដែលមានជាប់ជាមួយ
- គោលការណ៍នៃការពារមនុស្សទាំងអស់ដែលស្ថិតនៅក្រោមការឃុំឃាំងគ្រប់ប្រភេទ ឬជាប់ពន្ធនាគារ គោលការណ៍នេះបង្កើតនៅឆ្នាំ១៩៨៨

គោលការណ៍ទី ១
គោលការណ៍ទី ៦

> អ្នកទោសទាំងអស់ត្រូវគេប្រព្រឹត្តលើក្នុងភាពជាមនុស្ស មិនទទួលរងនូវទារុណកម្ម ឬអំពើព្រៃផ្សៃ អមនុស្សធម៌ ឬអំពើដែលធ្វើឱ្យខូចកិត្តិយស

មន្ត្រីពន្ធនាគារៈ

- មាត្រា៣២ I នៃរដ្ឋធម្មនុញ្ញ សិទ្ធិសេរីភាពបុគ្គល

#### ខ. តើស្ថាប័នពាក់ព័ន្ធមានភារកិច្ចតាមផ្លូវច្បាប់អ្វីខ្លះ?

ពន្ធនាគារៈ

មាត្រា៣៨ III នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលពាក់ព័ន្ធនឹងមាត្រា៣ ចំនុចទី១ នៃសេចក្តីប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ (ប្រកាសចុះថ្ងៃទី៣១ មិនា ១៩៩៨)ៈ ពន្ធនាគារត្រូវគ្រប់គ្រងដោយស្របទៅតាម "ច្បាប់ដែលពាក់ព័ន្ធនឹងច្បាប់ និងអនុសញ្ញាស្តីពីសិទ្ធិមនុស្ស" ។ នេះមានន័យថា រដ្ឋាភិបាលកម្ពុជាត្រូវធានាថា មិនមានការធ្វើទុក្ខបុកម្នេញ ឬទារុណកម្មអ្វីកើតឡើងនៅក្នុងពន្ធនាគារកម្ពុជាទេ ។

តុលាការៈ

មាត្រា១២៨ II នៃរដ្ឋធម្មនុញ្ញកម្ពុជាៈ តុលាការមានភារកិច្ចធានា និងលើកកំពស់ដោយមិនលំអៀង និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ។

### ៤. តើអត្ថន័យនៃពាក្យខុសៗគ្នានៅក្នុងមាត្រាច្បាប់សិទ្ធិមនុស្សមានអ្វីខ្លះ?

សិទ្ធិត្រូវគេប្រព្រឹត្តដាក់ដោយមេត្តាៈ

= ត្រូវបានគេការពារប្រឆាំងនឹងការបំពានរូបរាងកាយ និងផ្លូវចិត្ត និងមិនត្រូវបានគេដកហូតជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ នូវការប្រើវិញ្ញាណធម្មជាតិរបស់មនុស្សម្នាក់ ដូចជា ការឃើញ ការស្តាប់ ឬការដឹង អំពីទីកន្លែង ឬពេលវេលាពីអតីតកាលនោះឡើយ ។

និយមន័យនៃពាក្យ "ទារុណកម្ម" ដែលផ្ទុយស្រឡះពីការប្រព្រឹត្ត ដោយមេត្តា អាចត្រូវរកឃើញក្នុងមាត្រា១ I CAT (អនុសញ្ញាស្តីពីការប្រឆាំងនឹងទារុណកម្ម) ។

សិទ្ធិសេរីភាពបុគ្គលៈ

= ដើម្បីធ្វើនូវអ្វីដែលខ្ញុំចង់ធ្វើ

**៥.** តើមាត្រាច្បាប់សិទ្ធិមនុស្ស**អនុវត្ត**ទៅលើករណីជាក់ស្តែងដែរឬទេ?

អ្នករំលោភគេដែលត្រូវគេវាយ:

គាត់មិនចង់ត្រូវគេវាយទេ ។ ការវាយដំ គឺជាការបំពានរូបរាងកាយលើកន្លែងណាមួយដែលអ្នកខ្លះយ៉ាងហោច-ណាស់ ក៏អាចបាត់បង់ជាបណ្តោះអាសន្ននូវការដឹងពីទីកន្លែង ។ **ពិតមែន** មាត្រា៧ ឃ្លាទី១ និង មាត្រា១០ I ICCPR មាត្រា៣៨ IV ឃ្លាទី១ CC និង គោលការណ៍ទី១ ដល់ ទី៦ នៃគោលការណ៍នៃការការពារមនុស្សដែលស្ថិតនៅក្រោមការឃុំខ្លួន ឬដាក់ពន្ធនាគារគ្រប់ប្រភេទ ឆ្នាំ១៩៩៨ **អនុវត្ត**ចំពោះករណីនេះ ។

មន្ត្រីពន្ធនាគារ:

ពួកគេចង់បានពតិមានអំពីមនុស្សផ្សេងដែលរំលោភស្ត្រីច្រើននាក់ ។ ដើម្បីទទួលបាននូវពតិមាននេះ ពួកគេចង់ប្រើគ្រប់មធ្យោបាយដើម្បីស្វែងរកដោយមិនគិតអំពីផលវិបាកអ្វីឡើយ ។ ពួកគេចង់ធ្វើអ្វីដែលគេចង់ធ្វើ ។

**ពិតមែន** មាត្រា៣២ I CC **អនុវត្ត**ចំពោះករណីនេះ ។

**៦.** តើអ្វីខ្លះជា**ការដាក់កំហិត**លើសិទ្ធិមនុស្ស?

អ្នករំលោភគេដែលជាអ្នកទោស:

**គ្មាន**ការដាក់កំហិតណាមួយលើសិទ្ធិមនុស្សត្រូវបានធ្វើឡើងដោយមេត្តានៅក្នុង មាត្រា៧ ឃ្លាទី១, មាត្រា១០ I ICCPR និង **គ្មាន**ការដាក់កំហិតក្នុងមាត្រា៣៨ IV ១ CC មាត្រា២ ចំនុចទី២ CAT ទោះជាការបញ្ជាក់ថា "គ្មានករណីលើកលែងទេ ទោះក្នុងកាលៈទេសៈណាក៏ដោយ មិនថាស្ថានការណ៍សង្គ្រាម ឬ ការគំរាមកំហែងរបស់សង្គ្រាម អស្ថេរភាពនយោបាយអន្តរជាតិ ឬភាពបន្ទាន់សាធារណៈណាមួយ មិនអាចត្រូវគេសំអាងថា ជាការដោះសារនៃការធ្វើទារុណកម្ម"ឡើយ ។ នេះមានន័យថា ទោះជាស្ថិតក្នុងកាលៈទេសៈធ្ងន់ធ្ងរដូចដែលបាននិយាយខាងលើនេះ សិទ្ធិមនុស្សដែលត្រូវគេប្រព្រឹត្តលើដោយមេត្តា និងមិនត្រូវរងការធ្វើទារុណកម្ម **មិនអាចត្រូវបានដាក់កំហិត**ទេ "ការធ្វើទារុណកម្មស្រាលៗប្រភេទណាក៏ដោយ" មិនត្រូវបានអនុញ្ញាតទេ!

មន្ត្រីពន្ធនាគារ:

មាន**ការដាក់កំហិតតែមួយគត់**ទៅលើសិទ្ធិសេរីភាពក្នុងមាត្រា៣១ II ២ CC: "ការអនុវត្តសិទ្ធិ និងសេរីភាពបុគ្គលដោយរូបវ័ន្តបុគ្គលណាមួយ មិនត្រូវជះឥទ្ធិពលមិនល្អលើ**សិទ្ធិ និងសេរីភាពអ្នកដទៃ**នោះទេ ។ ការអនុវត្តន៍សិទ្ធិ និងសេរីភាពបែបនេះ ត្រូវឱ្យស្របទៅនឹងច្បាប់ ។"

មានន័យថា សិទ្ធិសេរីភាពអាចត្រូវបានដាក់កំហិតដោយសិទ្ធិ និងសេរីភាពរបស់អ្នកដទៃប៉ុណ្ណោះ ។

**៧.** តើមាន**ច្បាប់ពិសេស**ដែល**ចែងពីការដាក់កំហិត**លើសិទ្ធិមនុស្សដែរឬទេ?

អ្នករំលោភគេដែលជាអ្នកទោស:

មិនអាចមានច្បាប់ពិសេសទេ ព្រោះគ្មានការដាក់កំហិត!

មន្ត្រីពន្ធនាគារ:

មាត្រា១២ ចំនុច១ និង មាត្រា១២ ចំនុច២ នៃក្រមព្រហ្មទណ្ឌអន្តរកាល ជាមួយនឹងគោលការណ៍ទី១ និង ទី៦ នៃការការពារមនុស្សដែលស្ថិតនៅក្រោមការឃុំខ្លួន និងការជាប់ពន្ធនាគារគ្រប់រូបភាពទាំងអស់ (១៩៩៨) គឺជាច្បាប់ពិសេសដែលចែងអំពីការដាក់កំហិតលើ "សិទ្ធិ និងសេរីភាពអ្នកដទៃ" (មាត្រា៣១ II ២ CC) ។ មន្ត្រីពន្ធនាគារនេះមិនមានសិទ្ធិវាយដំអ្នករំលោភគេដើម្បីយកពតិមានបន្ថែមពីគាត់អំពីអ្នកធ្វើខុសផ្សេងនោះទេ ។ នៅក្នុងកាលៈទេសៈណាក៏ដោយ ក៏ការវាយដំរបស់ពួកគេមិនត្រឹមត្រូវទេ ទោះបីជាជនល្មើសផ្សេងទៀតមិនត្រូវបានរកឃើញ ហើយនិងបន្តការរំលោភលើស្ត្រីឯទៀតក៏ដោយ!

៨. តើការដាក់កំហិតដែលត្រូវអនុវត្តនោះ សមាមាត្រ ឬខ្លាំងហួសពេក? (“គោលការណ៍សមាមាត្រ”)

នៅក្នុងករណីរឿងនេះ យើងមិនត្រូវការពិនិត្យថាតើ វិធានការដែលចាត់ឡើងដោយមន្ត្រីពន្ធនាគារ សមាមាត្រ ឬអត់នោះទេ ព្រោះមិនមានការដាក់កំហិតលើសិទ្ធិរបស់អ្នកទោសត្រូវបានប្រព្រឹត្តលើដោយមេត្តា ។

ប្រសិនបើអនុសញ្ញាអន្តរជាតិ ឬរដ្ឋធម្មនុញ្ញកម្ពុជាមិនមានចែងអ្វីអំពីការដាក់កំហិតទេ នោះវិធានការដែលចាត់ឡើងដើម្បីដាក់កំហិតលើសិទ្ធិមនុស្សគឺមិនស្របច្បាប់ទេ : នោះមិនមានចន្លោះសំរាប់អំពើដែលសមស្របទេ ។

នៅក្នុងករណីរឿងនោះ បណ្តឹង (សូមមើល មាត្រា ៣៩ ឃ្លាទី១ នៃ CC: សិទ្ធិក្នុងការប្តឹងតវ៉ា) របស់អ្នកទោសដែលត្រូវគេវាយត្រូវបានបញ្ជាក់ថាត្រឹមត្រូវ ។

តុលាការដែលដោះស្រាយជម្លោះនេះ (មាត្រា៣៩ ឃ្លាទី២ នៃ CC ) ត្រូវដាក់ទោសមន្ត្រីពន្ធនាគារ ។ មាត្រា៣៨ IV ២ នៃ CC ចែងថា ជនណាប្រព្រឹត្ត ចូលរួម ឬសមគំនិត នឹងអំពើចាប់បង្ខំ ឬការធ្វើទុក្ខទោសម្មេញដល់រាងកាយ ត្រូវដាក់ទោសទៅតាមច្បាប់ ។ ច្បាប់នេះគឺ មាត្រា៥៧ ដែលពាក់ព័ន្ធនឹង មាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ មន្ត្រីពន្ធនាគារអាចប្រឈមមុខនឹងការដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៣ឆ្នាំ ។

## សំនួរសិក្សាទី ៩

ក. សូមរៀបរាប់បទបញ្ញត្តិច្បាប់ជាតិ និង អន្តរជាតិ ដែលការពារសិទ្ធិបញ្ចេញមតិដោយសេរី!

បទបញ្ញត្តិច្បាប់អន្តរជាតិ:

- មាត្រា១៩ នៃ UDHR (សេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្ស)
- មាត្រា១៩ ចំនុចទី ១ និងទី២ ICCPR (កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)
- មាត្រា៥ ឃ (៨) CERD (អនុសញ្ញាស្តីពីការលុបបំបាត់ការប្រកាន់ពូជសាសន៍)
- មាត្រា១៣ I CRC (អនុសញ្ញាស្តីពីសិទ្ធិកុមារ) គឺជាការការពារពិសេសសំរាប់សិទ្ធិក្នុងការនិយាយស្តីដោយសេរីរបស់កុមារ

បទបញ្ញត្តិច្បាប់ជាតិ:

- មាត្រា ៤១ I ១ នៃរដ្ឋធម្មនុញ្ញកម្ពុជា
- មាត្រា ១ និង មាត្រា២០ ឃ្លាទី២ នៃច្បាប់ស្តីពីសារពតិមាន
- មាត្រា២៨ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌអន្តរកាល

ខ. តើដោយសារមូលហេតុអ្វី បានជាសេរីភាពនៃការបញ្ចេញមតិត្រូវបានគេដាក់កំហិត? សូមរៀបរាប់នូវមូលហេតុទាំងអស់ដូចដែលមានចែងក្នុងអត្ថបទច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

មូលហេតុនៃការដាក់កំហិតនៅក្នុងអត្ថបទច្បាប់អន្តរជាតិ:

- មាត្រា២៩ ចំនុចទី២ UDHR: សេរីភាព (សេរីភាពក្នុងការនិយាយស្តីផងដែរ) អាចត្រូវបានដាក់កំហិតដោយច្បាប់ទាំងឡាយដែលមានគោលបំណងដើម្បីការពារ
  - សិទ្ធិ និងសេរីភាពអ្នកដទៃ
  - សីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និងសុខមាលភាពល្អ
- មាត្រា១៩ ចំនុចទី៣ ICCPR: សេរីភាពនៃបញ្ចេញមតិអាចត្រូវដាក់កំហិតបានដោយច្បាប់ទាំងឡាយដែលការពារ
  - សិទ្ធិ ឬកេរ្តិ៍ឈ្មោះអ្នកដទៃ
  - សន្តិសុខជាតិ
  - សណ្តាប់ធ្នាប់សាធារណៈ
  - សុខមាលភាពសាធារណៈ ឬ
  - សីលធម៌

មូលហេតុនៃការដាក់កំហិតនៅក្នុងអត្ថបទច្បាប់ជាតិ:

- មាត្រា ៤១ I ឃ្លាទី២ នៃរដ្ឋធម្មនុញ្ញ:
  - សិទ្ធិអ្នកដទៃ
  - ទំនៀមទំលាប់ល្អរបស់សង្គម
  - ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ
  - សន្តិសុខជាតិ
- មាត្រា៥ នៃរបបសារពត៌មាន:
  - សន្តិសុខជាតិ
  - ទំនាក់ទំនងជាមួយប្រទេសផ្សេងទៀត
  - សិទ្ធិរូបវ័ន្តបុគ្គល
  - ឯកសារសំខាន់ផ្នែកពាណិជកម្ម និងហិរញ្ញវត្ថុ
  - សិទ្ធិអ្នកដទៃក្នុងការទទួលបាននូវការជំនុំជំរះដ៏យុត្តិធម៌
  - មន្ត្រីសាធារណៈអនុវត្តច្បាប់
- មាត្រា៦២ នៃក្រមព្រហ្មទណ្ឌអន្តរកាលៈ
  - ការរំខានដល់សន្តិភាពសាធារណៈ
- មាត្រា៦៣ ចំនុចទី១ ឃ្លាទី១ នៃក្រមព្រហ្មទណ្ឌអន្តរកាលៈ
  - កិត្តិយស ឬកេរ្តិ៍ឈ្មោះអ្នកផ្សេង

## សំនួរសិក្សាទី ១០

អត្ថបទនៅក្នុងកាសែតតូចមួយ ដាក់ឈ្មោះអ្នកនយោបាយថាជា "ឆ្កែពុករលួយ– Corrupt dog" ។ អ្នកនយោបាយរូបនោះបានដាក់ពាក្យប្តឹងកាសែតនោះតាមផ្លូវតុលាការរដ្ឋប្បវេណី ។ តុលាការរដ្ឋប្បវេណីបង្ខំឱ្យខាងកាសែត បង់ពិន័យចំនួន ៥.០០០.០០០៛ (មាត្រា១០ V នៃច្បាប់ស្តីពីសារពត៌មាន) ។ កាសែតតូចនោះគ្មានលទ្ធភាពបង់ប្រាក់ពិន័យនេះទេ ហើយត្រូវបិទទ្វារទៀត ។

**ក.** តើការដាក់កំហិតសេរីភាពសារពត៌មានស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញដែរឬទេ?

ទេ ការដាក់កំហិតនេះមិនស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញទេ (ពិន័យជាប្រាក់ចំនួន៥.០០០.០០០៛) ។ *គោលបំណង* នៃការដាក់កំហិតនេះស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ (ការការពារសេរីភាពអ្នកដទៃ) ប៉ុន្តែ *កំរិត* នៃការដាក់កំហិតនេះមិនស្ថិតក្រោមរដ្ឋធម្មនុញ្ញទេ ។

ម្យ៉ាងទៀតៈ វាស្របនឹងរដ្ឋធម្មនុញ្ញដើម្បីពិន័យកាសែតក្នុងការដែលប្រើពាក្យជេរប្រមាថ ប៉ុន្តែវាមិនស្របធម្មនុញ្ញទេ ក្នុងការជ្រើសយកការពិន័យធ្ងន់ធ្ងរបែបនេះ ហើយធ្វើឱ្យកាសែតនោះត្រូវបិទ ។

ក្នុងន័យស៊ីជំរៅៈ

មាត្រា៤១ I ២ CC កំណត់អំពីព្រំដែននៃសេរីភាពសារពត៌មាន និងអនុញ្ញាតឱ្យអ្នកធ្វើច្បាប់ ដាក់កំហិតសេរីភាពនេះក្នុងគោលបំណងការពារ "សិទ្ធិរបស់អ្នកដទៃ" ។ ដោយផ្អែកលើ ការអនុញ្ញាតដែលមាន ធម្មនុញ្ញភាពនេះ មាត្រា១០ V នៃច្បាប់ស្តីពីសារពត៌មានចែងថា លទ្ធភាពក្នុងបង្ខំឱ្យមានការដាក់កំហិតចំពោះសេរីភាពសារពត៌មាន គឺដើម្បីការពារសិទ្ធិសេចក្តីថ្លៃថ្នូរបស់បុគ្គល (មាត្រា៣៨ II CC ) ប្រឆាំងនឹងការជេរប្រមាថ និងការបរិហារកេរ្តិ៍ ។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញគ្របដណ្តប់លើមាត្រា១០ នៃច្បាប់ស្តីពីសារពត៌មាន ។ កាសែតអាចត្រូវពិន័យជាប្រាក់ក្នុងការប្រើពាក្យ "ឆ្កែ" ដែលជាការប្រមាថអ្នកនយោបាយ ។

ប៉ុន្តែ រដ្ឋធម្មនុញ្ញគ្រាន់តែអនុញ្ញាតឱ្យមានការដាក់កំហិតសេរីភាព ដែលជាការចាំបាច់ដើម្បីការពារសិទ្ធិអ្នកដទៃ ("គោលការណ៍នៃភាពសមាមាត្រ") ប៉ុណ្ណោះ ។ នេះមានន័យថា កំរិតនៃការដាក់កំហិតតែងតែត្រូវរក្សានូវតុល្យភាពរវាងសិទ្ធិត្រូវកំហិត (សេរីភាពសារពត៌មាន) និងសិទ្ធិត្រូវការពារ (សេចក្តីថ្លៃថ្នូរ) ។

មាត្រា១០ V នៃច្បាប់ស្តីពីសារពត៌មានផ្តល់ជំរើសឱ្យតុលាការក្នុងការដាក់ឱ្យអនុវត្តពិន័យពី ១០០.០០០៛ ដល់ ៥.០០០.០០០៛ ដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ប្រឆាំងនឹងការជេរប្រមាថ ។ ដូច្នេះ នៅពេលដែលតុលាការអនុវត្តមាត្រា១០ V នៃច្បាប់ស្តីពីសារពត៌មាន តុលាការត្រូវថ្លឹងថ្លែងរវាងសេរីភាពសារពត៌មាន និងសិទ្ធិទទួលបាននូវសេចក្តីថ្លៃថ្នូរ ។ ហេតុដូច្នេះ តុលាការអាចគ្រាន់តែអនុវត្តពិន័យដែលធ្ងន់ល្មម ដើម្បីការពារសេចក្តីថ្លៃថ្នូរ ប៉ុន្តែមិនធ្ងន់ធ្ងរដល់ថ្នាក់បង្ខំឱ្យបិទសារពត៌មាននោះទេ ។

នៅក្នុងករណីដែលបានលើកឡើងខាងលើ ការពិន័យមានលក្ខណៈធ្ងន់ធ្ងរណាស់ ពីព្រោះបានបង្ខំឱ្យកាសែតបិទទ្វារ ។

ដូច្នេះ ការដាក់កំហិតនេះមិនស្ថិតក្រោមរដ្ឋធម្មនុញ្ញទេ ។

**ខ.** តើប្រតិកម្មអ្វីខ្លះរបស់តុលាការដែលអាចមានការសមាមាត្រនឹងករណីនេះ?

តុលាការអាចបង្ខំឱ្យអនុវត្តការដាក់កំហិតដែលមានលក្ខណៈស្រាលជាងនេះ ដែលមិនបង្ខំឱ្យកាសែតបិទទ្វារ ប៉ុន្តែវាអាចផ្តល់ការឈឺចាប់សមល្មមហើយសំរាប់កាសែត ឱ្យរាងចាលក្នុងការសរសេរជេរប្រមាថម្តងទៀតនោះ ។

ឧទាហរណ៍:
- តុលាការបង្ខំឱ្យអនុវត្តពិន័យត្រឹមតែ ១០០.០០០៛ (មាត្រា១០ V នៃច្បាប់សារពត៌មាន) ប្រសិនបើការពិន័យនោះនៅតែមានចំនួនច្រើន និងអាចបង្ខំឱ្យកាសែតបិទទ្វារនោះ
- តុលាការអាចបញ្ជាឱ្យកាសែតចុះផ្សាយជាសាធារណៈនូវការដកពាក្យមកវិញ (ឬការសុំទោសជាសាធារណៈ) (មាត្រា ១០ III នៃច្បាប់សារពត៌មាន) ឬ
- តុលាការអាចបញ្ជាឱ្យសងសំណងទៅអ្នកនយោបាយរូបនោះសំរាប់ការខូចកេរ្តិ៍ឈ្មោះ និងសេចក្តីថ្លៃថ្នូររបស់គាត់ ។

គ. ចូរពិនិត្យមើលការដាក់កំហិតទៅលើសេរីភាពសារពត៌មានក្នុងមាត្រា១២ I នៃច្បាប់សារពត៌មាន ។ តើពាក្យពីរខុសគ្នា "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ" ស្របទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជាដែរឬទេ?

មាត្រា៤១ I ២ CC អនុញ្ញាតឱ្យមានការដាក់កំហិតទៅលើសេរីភាពសារពត៌មានតែទៅលើគោលបំណងមួយចំនួនដែលបានកំណត់តែប៉ុណ្ណោះ ។ មាត្រានេះរៀបរាប់អំពីគោលបំណងច្បាស់លាស់ចំនួន៤ ផ្សេងៗគ្នា ។ គោលបំណងទាំង៤ នោះគឺ:

- ដើម្បីការពារសិទ្ធិរបស់អ្នកដទៃ
- ដើម្បីការពារប្រពៃណីដ៏ល្អរបស់សង្គម
- ដើម្បីការពារច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ
- ដើម្បីការពារសន្តិសុខជាតិ

មានតែក្នុងករណីដែលរៀបរាប់ច្បាស់លាស់ទេ ទើបអ្នកធ្វើច្បាប់ អាចធ្វើច្បាប់ដាក់កំហិតលើសិទ្ធិសេរីភាពសារពត៌មានបាន ។ ក្នុងករណីផ្សេងទៀតដែលមិនមានចែងនៅក្នុងមាត្រា៤១ I ២ CC ការដាក់កំហិតមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ។

ហេតុដូច្នេះមាត្រា១២ I នៃច្បាប់ស្តីពីសារពត៌មាន ត្រូវស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ ព្រោះច្បាប់នេះចែងដាក់កំហិតលើសិទ្ធិសេរីភាពសារពត៌មានក្នុងគោលបំណងការពារ "សន្តិសុខជាតិ" ប៉ុណ្ណោះ ។ ប៉ុន្តែមាត្រា១២ I នៃច្បាប់ស្តីពីសារពត៌មាន មិនស្ថិតក្រោមរដ្ឋធម្មនុញ្ញទេ ព្រោះថា វាដាក់កំហិតទៅលើសេរីភាពសារពត៌មាន**ក្នុងគោលបំណងការពារ "ស្ថេរភាពនយោបាយ"** ជាការងាយស្រួលបកស្រាយទេ ព្រោះថាគោលបំណងនេះ**មិនមានចែងនៅមាត្រា៤១ I ២ CC** ទេ ។

ស្ថេរភាពនយោបាយ អាចជាតម្លៃវិជ្ជមានមួយសំរាប់សង្គមដែលមានបញ្ហា ។ ប៉ុន្តែពាក្យថា "ស្ថេរភាពនយោបាយ" នេះមានន័យទូលំទូលាយ និងមិនច្បាស់លាស់ទេ ។ តើអ្វីជាស្ថេរភាពនយោបាយ? តើអ្នកណាអាចឱ្យនិយមន័យពាក្យនេះឱ្យបានច្បាស់លាស់ដែលឱ្យប្រជាពលរដ្ឋយល់ជាមុនថា អ្វីខ្លះត្រូវបានអនុញ្ញាត និងអ្វីខ្លះមិនត្រូវបានអនុញ្ញាត ? ការអនុញ្ញាតឱ្យមានការដាក់កំហិតលើសេរីភាពសារពត៌មានដើម្បីការពារ "ស្ថេរភាពនយោបាយ និងបើកផ្លូវសំរាប់រដ្ឋាភិបាលដាក់កំហិតលើការបញ្ចេញមតិរិះគន់ ឬប្រឆាំង ឬការពិភាក្សាដោយសេរី ដោយគ្រាន់តែហៅសកម្មភាពទាំងនោះថាជា "ការគំរាមកំហែងដល់ស្ថេរភាពនយោបាយ" ។ ហេតុដូច្នេះ រដ្ឋធម្មនុញ្ញមិនត្រូវអនុញ្ញាតឱ្យមានការដាក់កំហិតលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពសារពត៌មានដើម្បីការពារ "ស្ថេរភាពនយោបាយ" នោះទេ ។ ដូច្នេះជាមូលដ្ឋានរដ្ឋធម្មនុញ្ញអនុញ្ញាតឱ្យមានការដាក់កំហិតតែចំពោះការបញ្ចេញមតិដោយសេរី បើវាធ្វើឱ្យខូចកិត្តិយសអ្នកដទៃដោយសារការជេរប្រមាថឬការបរិហារកេរ្តិ៍ ឬ បើវារំខានដល់សណ្តាប់ធ្នាប់សាធារណៈដោយមានចេតនាញុះញង់ប្រជាពលរដ្ឋឱ្យប្រព្រឹត្តអំពើហិង្សា ឬ បើវាបង្កគ្រោះថ្នាក់ដល់សន្តិសុខជាតិឧទាហរណ៍បង្ហាញឱ្យគេដឹងអំពីការសម្ងាត់យោធា ។

## សំណួរសិក្សាទី ១១

ចូរអានច្បាប់សារពត៌មាន ។

ក. តើច្បាប់ស្តីពីសារពត៌មានអនុញ្ញាតឱ្យមានការត្រួតពិនិត្យជាមុនដែរឬទេ? ចូរលើកនូវវិធានទាំងឡាយដែលពាក់ព័ន្ធ។

ជាទូទៅ: ការត្រួតពិនិត្យជាមុនមានន័យថា ការយល់ព្រមជាមុនលើអត្ថបទដែលបោះផ្សាយជាសាធារណៈរបស់បណ្តាបណ្តាញឃោសនារបស់រដ្ឋាភិបាលក្នុងគោលបំណងចែកចាយ និងលាក់បាំងពត៌មាន ។ បើគ្មានការអនុញ្ញាតទេ គឺវាមិនស្របច្បាប់ទេ ។

ការរិះគន់មានន័យថា ជាសំពាធលើអ្នកកាសែត និងលាក់បំពួនពួកគេពីការបំពេញភារកិច្ចវិជាជីវៈរបស់ខ្លួន ។

ដើម្បីជៀសវាងបញ្ហានេះ មាត្រា៣ នៃច្បាប់ស្តីពីសារពត៌មានចែងថា: "ដើម្បីថែរក្សាឯករាជភាពនៃសារពត៌មានការត្រួតពិនិត្យមុនការបោះពុម្ពផ្សាយត្រូវហាមឃាត់ ។"

សំគាល់:

- មាត្រា១០ I ១ នៃច្បាប់ស្តីពីសារពត៌មាន មិនអនុញ្ញាតឱ្យមានការត្រួតពិនិត្យជាមុនទេ ប៉ុន្តែ នេះជាមូលដ្ឋានច្បាប់ក្នុងការប្តឹងចំពោះការបោះពុម្ពផ្សាយពត៌មានមិនពិត ដែលអាចប៉ះពាល់ដល់កិត្តិយស ឬសេចក្តីថ្លៃថ្នូររបស់មនុស្ស ឬក្នុងករណីរឿងសាធារណៈ (ដូចជាអ្នកនយោបាយជាដើម) ប្រសិនបើ ពត៌មានមិនពិតត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយមានចេតនាព្យាបាទ ។ ដូចអ្នកបានឃើញនៅក្នុង មាត្រា១០ III IV V និង VI វាអាស្រ័យលើតុលាការ (មិនមែនរដ្ឋាភិបាលទេ) ដែលត្រូវសំរេចថា តើពត៌មានដែលបានបោះផ្សាយជាសាធារណៈនោះពិត ឬមិនពិត ។
- មាត្រា១១ ១២ ១៣ ១៤ និង ១៥ នៃច្បាប់ស្តីពីសារពត៌មាន មិនបានបញ្ញត្តិអំពីការត្រួតពិនិត្យជាមុនទេ ប៉ុន្តែបញ្ជាក់អំពីការដាក់កំហិតលើសេរីភាពក្នុងការនិយាយស្តីសំរាប់បណ្តាញសារពត៌មាន ។

ប្រយ័ត្ន: មាត្រា១២ III នៃច្បាប់ស្តីពីសារពត៌មាន អាចត្រូវបំពាន ដូចជាការត្រួតពិនិត្យក្រោយពេលបោះពុម្ពផ្សាយ (ដូច្នេះ វាអាចមានន័យថាជាការគំរាមកំហែងដល់អ្នកកាសែត និងបណ្តាសារពត៌មាន) ដោយរដ្ឋាភិបាល ព្រោះក្រសួងពត៌មាន និងក្រសួងមហាផ្ទៃ មានសិទ្ធិរឹបអូសការបោះពុម្ពផ្សាយរបស់សារពត៌មានដែល "ប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ" (សូមមើលមាត្រា១២ I នៃច្បាប់ស្តីពីសារពត៌មាន) ។ តុលាការកម្ពុជា ឬអ្នកធ្វើច្បាប់ មិនទាន់បានកំណត់ច្បាស់លាស់នៅឡើយទេ ថាតើ "សន្តិសុខជាតិ" និងស្ថេរភាពនយោបាយ" មានន័យពិតប្រាកដថាយ៉ាងដូចម្តេច ។ មានការបកស្រាយច្រើន និងជាគ្រោះថ្នាក់មួយដែលរដ្ឋាភិបាលនឹងកំណត់និយមន័យតាមទំនើងចិត្តនូវពាក្យច្បាប់ដែលមានន័យមិនច្បាស់លាស់ ដើម្បីគោលបំណងនយោបាយរបស់ខ្លួនដោយគ្មានសវនាការសាធារណៈជាមុនរបស់សង្គមនោះទេ ។

ខ. មាត្រា២០ នៃច្បាប់ស្តីពីសារពត៌មានយោងទៅលើការបំពានក្រមព្រហ្មទណ្ឌដែលធ្វើទៅបាន ។ សូមធ្វើការរៀបរាប់ដោយប្រុងប្រយ័ត្ន!

មាត្រា ៤៨, ៤៩, ៥០, ៥៩, ៦០, ៦១, ៦២ និង ៦៣ នៃក្រមព្រហ្មទណ្ឌអន្តរកាល

គ. សំណុំរឿង

សមាជិកទាំងឡាយរបស់ "សមាគមគ្រូបង្រៀន" ពិភាក្សាអំពីប្រាក់បៀវត្ស និងលទ្ធភាពទៅរកការធ្វើកូដកម្ម ។ អភិបាលខេត្តអះអាងថា ការពិភាក្សានេះមិនស្របច្បាប់ទេ ព្រោះវាជាការគំរាមកំហែងដល់"សន្តិសុខជាតិ និងថាប្រាក់បៀវត្សខ្ពស់អាចបង្កឱ្យមានការខូចខាតដល់ថវិកាជាតិ ។ បន្ទាប់អភិបាលខេត្តបានហាមឃាត់កិច្ចពិភាក្សានោះ ។

តើការហាមឃាត់នេះស្របច្បាប់ ឬមិនស្របច្បាប់?

១. ដោយអង្គុយជាមួយគ្នា និងការពិភាក្សាអំពីប្រាក់បៀវត្សរបស់គ្រូបង្រៀនដែលបានអនុវត្តសិទ្ធិរបស់ខ្លួនលើសេរីភាពក្នុងការនិយាយស្តីដូចដែលមានចែងក្នុងមាត្រា៤១ I ១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។

២. ដោយការហាមឃាត់កិច្ចពិភាក្សារបស់អភិបាលខេត្ត ផ្អែកលើ "សន្តិសុខជាតិ" ថាជាការដាក់កំហិតមួយក្នុងចំណោមការដាក់កំហិតច្រើនទៀតលើសេរីភាពក្នុងការនិយាយ មាត្រា៤២ I ២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។

ពាក្យច្បាប់ថា "សន្តិសុខជាតិ" មិនបានកំណត់និយមន័យនៅក្នុងច្បាប់ទេ ។ ដោយសារ ពាក្យនេះជាការដាក់កំហិតមួយលើសិទ្ធិមួយក្នុងចំណោមសិទ្ធិមនុស្សជាមូលដ្ឋាន ដូច្នេះនិយមន័យរបស់ពាក្យនេះត្រូវតែមានន័យចង្អៀត និងមិនអាចថាជាផលប្រយោជន៍សន្តិសុខណាមួយរបស់រដ្ឋាភិបាលបានទេ ។

ដើម្បីកំណត់និយមន័យពាក្យនេះ មាត្រា៥២ នៃរដ្ឋធម្មនុញ្ញ ដែលចែងអំពីកាតព្វកិច្ចទូទៅរបស់រាជរដ្ឋាភិបាលកម្ពុជា អាចជួយបាន: "រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារឯករាជភាព អធិបតេយ្យភាព បូរណភាពដែនដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តគោលនយោបាយផ្សះផ្សាជាតិ ដើម្បីធានានូវឯកភាពជាតិ និងរក្សានូវទំនៀមទំលាប់ល្អរបស់ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវរក្សា និង ការពារច្បាប់ និង ធានានូវសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។ ..."

អត្ថបទនៃមាត្រានេះបង្ហាញថា "សន្តិសុខជាតិ"អាចមានតែមួយថាជា ការគំរាមកំហែងដល់ប្រទេសកម្ពុជាទាំងមូល និងជាគ្រោះថ្នាក់ដល់អាយុជីវិត និងសន្តិសុខរបស់ប្រជាជនទាំងមូល ដូចជា បណ្តាលមកពីការវាយប្រហារដោយយោធារបស់ប្រទេសផ្សេង ឬការញុះញង់ឱ្យមានអំពើហិង្សាទៅលើរដ្ឋាភិបាល (សូមមើល "គោលការណ៍ Johannesburg " មាត្រា១ I, II មាត្រា២, ៦ និង ៧ (www.hrni.org/~lhennebe/files/instruments/HRNi EN 470.rtf)

**លទ្ធផល:** កិច្ចពិភាក្សាប្រកបដោយសន្តិវិធីរបស់គ្រូបង្រៀនអំពីប្រាក់បៀវត្ស មិនមែនជាការគំរាមកំហែងដល់ "សន្តិសុខជាតិ"ទេ ទោះបីជាត្រូវពាក់ព័ន្ធនឹងថវិកាជាតិក៏ដោយ ។ ការហាមឃាត់របស់អភិបាលខេត្តគឺមិនស្របច្បាប់ទេ ។

## សំនួរសិក្សាទី ១២

សូមអានជំពូកទី៧ ចំណុច ៧.១២.១៤ នៃបទបញ្ជារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ។

> "គជប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬសម្ភារៈអប់រំទាំងអស់ ដែលមិនគោរពទៅតាមចំណុច ៧.១២.៣ និង ៧.១៣.៨ ។ សាមីអង្គការត្រូវធ្វើការកែតម្រូវតាមសំណើររបស់ គជប ជាចាំបាច់ ។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាម មាត្រា១៣១ នៃច្បាប់បោះឆ្នោត ។"

តើជំពូក៧, ១២, ១៤ នៃបទបញ្ជាបំពាននឹងច្បាប់ស្តីពីការបោះឆ្នោតដែរឬទេ?
ចូរឱ្យមូលហេតុចំពោះចម្លើយរបស់អ្នក!

បទបញ្ជារបស់ គជប (ជំពូក ៧.១២.១៤) មិនមានមូលដ្ឋានផ្អែកលើច្បាប់នោះទេ ។ បទបញ្ជារបស់ គជប បំពានមាត្រា ១៣១ នៃច្បាប់ស្តីពីការបោះឆ្នោត ព្រោះថា មាត្រានេះផ្តល់អំណាចឱ្យ គជប ត្រឹមតែដាក់ទោសគណៈបក្សនយោបាយចំពោះសកម្មភាពឃោសនាខុសច្បាប់ប៉ុណ្ណោះទេ (មាត្រា ៧៣ ដល់ ៧៦) ប៉ុន្តែមិនដាក់ទោសអង្គការមិនមែនរដ្ឋាភិបាលដែលចែកចាយឯកសារអប់រំអ្នកបោះឆ្នោតអព្យាក្រឹត្យនោះទេ ។ NGO មិនមែនជាគណៈបក្សនយោបាយទេ ។ NGO មិនអាចធ្វើការឃោសនាបានទេ ព្រោះពួកគេមិនឈរឈ្មោះឱ្យគេបោះឆ្នោតទេ ហើយការអប់រំអ្នកបោះឆ្នោតមិនមែនជាការផ្តល់ពត៌មានអំពីកម្មវិធីនយោបាយរបស់គណៈបក្សនោះទេ (សូមមើល មាត្រា៧០ នៃច្បាប់បោះឆ្នោត) ។ ដូច្នេះ បទបញ្ជារបស់ គជប គឺខុសច្បាប់ ព្រោះវាមិនផ្អែកទៅតាមច្បាប់ ។

## សំណួរសិក្សាទី ១៣

ក. ចូរអានច្បាប់បោះឆ្នោត!
តើមាត្រាណាខ្លះនៃច្បាប់បោះឆ្នោតចែងអំពីទោសសំរាប់ទង្វើដែលជះឥទ្ធិពលអវិជ្ជមានលើដំណើរការបោះឆ្នោត? សូមរៀបរាប់មាត្រា និងលេខមាត្រា!

មាត្រា១២២ ដល់ មាត្រា១៣៣ នៃច្បាប់ស្តីពីការបោះឆ្នោត

ខ. តើមាត្រាណាខ្លះនៃក្រមព្រហ្មទណ្ឌចែងអំពីទោសសំរាប់ទង្វើដែលជះឥទ្ធិពលអវិជ្ជមានលើដំណើរការបោះឆ្នោត? សូមរៀបរាប់មាត្រា និងលេខមាត្រា:

មាត្រា ៦៤ នៃក្រមព្រហ្មទណ្ឌ

គ. តើមាត្រាណាខ្លះនៃច្បាប់ស្តីពីការបោះឆ្នោត និង ក្រមព្រហ្មទណ្ឌហាមឃាត់ការទិញសន្លឹកឆ្នោត?

មាត្រា១២៤ ចំនុចទី១០នៃច្បាប់បោះឆ្នោតចែងថា:

ជនណាម្នាក់ ឬគណៈបក្សនយោបាយណាមួយដែលផ្តល់ជាសំភារៈ ឬប្រាក់ដើម្បីទិញសន្លឹកឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះគណៈបក្សដែលចូលរួមក្នុងការបោះឆ្នោត ហើយត្រូវលុបបេក្ខភាពរបស់ជននោះត្រូវលុបចោលដោយ គជប និង/ឬ ជននោះត្រូវពិន័យជាប្រាក់ចំនួនពី ៥.០០០.០០០៛ ដល់ ២៥.០០០.០០០៛ ដោយមិនទាន់គិតពីទោសព្រហ្មទណ្ឌដទៃទៀតផង ។



## ករណីសិក្សាទី ២

សម្តេចសង្ឃ **ទេព វង្ស** បានចេញ "ប្រកាស" មួយដែលហាមឃាត់ដល់លោកសង្ឃទាំងអស់មិនឱ្យទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣នេះទេ ។

តើគាត់ធ្វើបែបនេះស្របច្បាប់ដែរឬទេ?

ប្រើបញ្ជីផ្ទៀងផ្ទាត់នៅដែលបង្ហាញនៅទំព័រទី៣៣ រួចហើយឆ្លើយនូវសំនួរទាំងអស់នោះម្តងមួយៗ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សង្ឃប្រកាស

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី ១១ បានប្រារព្ធពិធីបើកនៅសាលសន្និសីទចតុមុខ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** ហើយបានដំណើរការអស់ថេរវេលាពាថ្ងៃ ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០២ នៅក្រសួងធម្មការ និង សាសនា ក្រោមព្រះរាជាធិបតីភាពសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ដោយ មានមន្ត្រីសង្ឃចំនួន ១២៦ អង្គ ចូលរួមជាសមាជិក និងមន្ត្រីធម្មការ និង សាសនា ចំនួន ៨០រូប ជាអ្នកសង្កេតការណ៍ ។ ដោយយោងតាមព្រះរាជបន្ទូលរបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃនេះ បានចេញសង្ឃប្រកាស ដែលមានខ្លឹមសារដូចខាងក្រោម :

**១_ពង្រឹងការបដិបត្តិធម៌វិន័យ :**

-មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ធ្វើជាគម្រូក្នុងការគោរព បដិបត្តិត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និង អភិសមាចារ ។

-យកព្រះទ័យទុកដាក់ បង្រៀនណែនាំភិក្ខុគ្រប់រូបឱ្យចេះវិធីធ្វើសង្ឃកម្មនានា ចេះសំដែងភិក្ខុបាតិមោក្ខ និង ចូលរួមធ្វើឧបោសថកម្ម បានទៀងទាត់តាមកាលកំណត់ក្នុងព្រះវិន័យ ។

-អប់រំណែនាំ ភិក្ខុសាមណេរ ដែលជ្រុលប្រព្រឹត្តខុសឆ្គង ចេះស្ទ័យភ្ញាក់រលឹក កែលំអ ខ្លួនឯងដើរត្រូវតាមគន្លងពុទ្ធវិន័យវិញ ។

-ខិតខំអប់រំ ពុទ្ធបរិស័ទ ឱ្យចេះតំកល់ខ្លួនប្រកបដោយសទ្ធានិងបញ្ញា ប្រតិបត្តិត្រឹមត្រូវតាមពុទ្ធឱវាទ លះបង់ជំនឿផ្តេសផ្តាស ប្រាសចាកគន្លងព្រះពុទ្ធសាសនាដោយគ្មានហេតុផល ហើយជ្រះថ្លាស្មោះស្ម័គ្រចូល រួមទ្រទ្រង់ ជាតិ សាសនា ព្រះមហាក្សត្រ ។

**២_ពង្រឹងគុណភាពដឹកនាំ :**

-បន្តពង្រឹងរចនាសម្ព័ន្ធមន្ត្រីសង្ឃ និងជំរុញការ តែងតាំងមន្ត្រីសង្ឃពេញសិទ្ធិឱ្យបានឆាប់រហ័ស ។

-បំប៉នអំពីតួនាទី ភារកិច្ច របៀបបទរដ្ឋបាល ដល់មន្ត្រីសង្ឃ គណៈកម្មការ អាចារ្យវត្ត សំដៅគ្រប់គ្រងវត្តអារាម ធានាបានប្រសិទ្ធភាពខ្ពស់ ។

-ត្រូវចារបញ្ជាក់ថា បានសិក្ខ លើសង្ឃដីកា ឬឆាយា នៃបព្វជិតដែលបានលាចាកសិក្ខាបទទៅជាគ្រហស្ថ វិញ ។

-២-

៣.**ពង្រីកគុណភាពពុទ្ធិកសិក្សា** :

-ជំរុញការពង្រឹង ពង្រីក (កម្រង) ប្រព័ន្ធ សាលាពុទ្ធិកបឋមសិក្សា . សាលាធម្មវិន័យ និង មជ្ឈមណ្ឌលវិបស្សនា គ្រប់ស្រុក-ខ័ណ្ឌ ទូទាំងប្រទេស ។

-បន្តការពង្រឹងពង្រីកសហគមន៍សង្ឃ ទ្រទ្រង់ពុទ្ធិកសិក្សា និងពុទ្ធិកសង្គហកុមារ នៅតាម វត្តអារាម ។

-ខិតខំអប់រំកុមារនិងយុវជនកំព្រា ក្រីក្រ ដែលស្នាក់អាស្រ័យនៅក្នុងវត្តអារាម ឱ្យប្រកាន់ ខ្ជាប់នូវ សណ្តាប់ធ្នាប់ បញ្ញាសីល និងចរិយាធម៌ ។

-មន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ មានព្រះគ្រូចៅអធិការជាដើម ទូទាំងប្រទេសត្រូវធ្វើការបណ្តុះ បណ្តាលបព្វជិត និងគ្រហស្ថ ដើម្បីឱ្យទៅជាគ្រូបង្គោល ពុទ្ធិកសង្គហកុមារ ។

៤.**ព្រះសង្ឃនិងការបោះឆ្នោតគាំទ្រគណបក្សនយោបាយ** :

-ព្រះសង្ឃទាំងបច្ចុប្បន្ន ទាំងអនាគត ត្រូវប្រកាន់គោលជំហរអព្យាក្រឹត មិនចូលរួមបោះឆ្នោត គាំទ្រគណបក្សនយោបាយណាមួយឡើយ ប៉ុន្តែត្រូវរក្សាសិទ្ធិបោះឆ្នោតនេះនៅពេលអនាគតដែលមានការចាំ បាច់បំផុត ។

-ពិនិត្យរារាំងនូវគ្រប់រូបភាពអសកម្ម ដែលឆ្លៀតឱកាសយកព្រះសង្ឃ ឬ ព្រះពុទ្ធសាសនា ទៅ ប្រើប្រាស់ខុសចាកគន្លងធម៌វិន័យ ។

-មិនអនុញ្ញាតឱ្យមានអន្តរសាសនាណាមួយ ដែលប្រព្រឹត្តប្រាសចាកប្រពៃណី ទំនៀមទំលាប់ ខ្មែរ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៥.**ការទប់អធិករណ៍** :

-មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ត្រូវមានកម្មវិធីអប់រំភិក្ខុ សាមណេរ គណៈកម្មការ អាចារ្យ វត្ត ពង្រឹងសាមគ្គីភាពផ្ទៃក្នុង រារាំងគ្រប់រូបភាពអធិករណ៍ កុំឱ្យកើតមានក្នុងវត្តអារាម ។

-ប្រកាន់ជំហរម្ចាស់ការដោះស្រាយរាល់អធិករណ៍ ដែលជាសមត្ថកិច្ចខ្លួន ដោយប្រកាន់ គោលការណ៍ សម្រុះសម្រួលផ្សះផ្សារជាកត្តាគន្លឹះ ។

៦.**ការទប់អភិបាលកិច្ចសង្ឃ** :

-អភិបាលកិច្ចសង្ឃ ត្រូវចុះស្រាវជ្រាវរាល់បាតុភាព អធិករណ៍ ដែលកើតមានឡើង ដោយ សហការជាមួយមន្ត្រីសង្ឃ មន្ត្រីធម្មការមូលដ្ឋាន ។

-អភិបាលកិច្ចសង្ឃខេត្ត-ក្រុង គ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយ មន្ត្រីធម្មការ និងសាសនា រាល់ការដោះស្រាយអធិករណ៍ ។

-៣-

៧. អបអរសាទរសន្និសីទកំពូលពុទ្ធសាសនាលើកទី ៣ :

ចូលរួមអបអរសាទរដោយធ្វើសកម្មភាពជាក់ស្ដែង :

- ព្រះមេគណ ឬ អនុគណ ត្រូវណែនាំព្រះគ្រូចៅអធិការ ព្រះសង្ឃ ឱ្យរៀបចំវត្តអារាមឱ្យមានអនាម័យ និងដាំកូនឈើឱ្យមានសម្រស់បរិស្ថានធម្មជាតិ គួរជាទីជ្រះថ្លា គោរពបូជារបស់ពុទ្ធបរិស័ទ និងភ្ញៀវទេសចរទូទៅ ។

- ចំពោះវត្តអារាមដែលមានសម្បត្តិវប្បធម៌ ប្រាង្គ ប្រាសាទ បេតិកភណ្ឌជាតិ រមណីយដ្ឋាននិងតំបន់ទេសចរ ត្រូវខិតខំថែទាំយ៉ាងម៉ឺងម៉ាត់ ធានាបានទាំងរបៀបរៀប រយទាំងសុវត្ថិភាព ។

- មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ព្រមទាំងព្រះធម្មកថិក ត្រូវទេសនា ជួយអប់រំ បំបាត់អបាយមុខទាំងបីប្រការ ( ល្បែង . ស្រា . ស្រី) ដើម្បីឱ្យប្រជាពលរដ្ឋ មានការភ្ញាក់រលឹកកាត់បន្ថយ ដោយស្ម័យប្រវត្តិ ។

សង្ឃប្រកាសនេះ ជាច្បាប់សម្រាប់អនុវត្តនៅគ្រប់វត្តអារាម ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

រាល់លិខិតបទដ្ឋានណា ដែលផ្ទុយពីខ្លឹមសារ នៃសង្ឃប្រកាសនេះ ទុកជានិរាករណ៍ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០២

សម្ដេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ
ព្រះសុគន្ធាធិបតី

សម្ដេចព្រះសង្ឃរាជ បួរ គ្រី

សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ
ព្រះមហាសុមេធាធិបតី

បានឃើញ និងឯកភាព
រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

ជា . សាវឿន

# បញ្ជីផ្ទៀងផ្ទាត់ដើម្បីដោះស្រាយករណីសិទ្ធិមនុស្ស!

## ១. តើបុគ្គល និងស្ថាប័នណាខ្លះដែលពាក់ព័ន្ធវិវាទ?

សម្តេចសង្ឃរាជ (ក) បញ្ជាព្រះសង្ឃក្រោមបង្គាប់ដទៃទៀត (ខ) មិនឱ្យទៅបោះឆ្នោត ។ គេបានសំណូមពរឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) (គ) ពិនិត្យមើលថាតើការបញ្ជានេះវាអនុលោមទៅតាមច្បាប់បោះឆ្នោតឬទេ ។




## ២. តើអ្វីទៅជាផលប្រយោជន៍របស់បុគ្គល ឬស្ថាប័នដែលពាក់ព័ន្ធនោះ ហើយតើពួកគេមានទំនាក់ទំនងនឹងគ្នាយ៉ាងណាខ្លះ?



## ៣. សិទ្ធិ និងភារកិច្ចៈ

### ក. តើសិទ្ធិណាខ្លះដែលត្រូវប៉ះពាល់?

ក

- សេរីភាពក្នុងការបញ្ចេញមតិ
- សេរីភាពខាងសាសនា

ខ

- សិទ្ធិក្នុងការបោះឆ្នោតដោយសេរី

សម្ដេចសង្ឃរាជ (ក) គឺជាបុគ្គលមួយអង្គនៃសាសនា ។ ព្រះអង្គបានអះអាងអំពីហេតុផលសាសនា ដើម្បីគាំទ្រគោលជំហររបស់ព្រះអង្គ ។ ដូច្នេះព្រះអង្គអាចអះអាងថាព្រះអង្គគ្រាន់តែអនុវត្តនូវសិទ្ធិសេរីភាពខាងជំនឿសាសនាប៉ុណ្ណោះនៅពេលដែលព្រះអង្គបញ្ជាមិនឱ្យព្រះសង្ឃដទៃទៀតទៅបោះឆ្នោតនោះ ។ សម្ដេចសង្ឃរាជ ក៏បានសរសេរជាប្រកាសដោយបង្ហាញនូវគោលជំហររបស់ព្រះអង្គថា ព្រះសង្ឃមិនគួរទៅបោះឆ្នោតឡើយ ។ ដូច្នេះព្រះអង្គក៏អាចអះអាងថាព្រះអង្គអនុវត្តនូវសិទ្ធិខាងការបញ្ចេញមតិដោយសេរី ។

ព្រះសង្ឃក្រោមបង្គាប់(ខ)ចង់ទៅបោះឆ្នោត ។ ដូច្នេះសិទ្ធិរបស់លោកក្នុងការបោះឆ្នោតអាចត្រូវប៉ះពាល់ ។ លោកចង់ទៅបោះឆ្នោតដោយគ្មានការគាបសង្កត់ នៅក្នុងដំណើរការបោះឆ្នោតដោយសេរី ដូច្នេះ សិទ្ធិក្នុងការបោះឆ្នោតដោយសេរី អាចត្រូវប៉ះពាល់ដោយការគាបសង្កត់អំពីការបញ្ជារបស់សម្ដេចសង្ឃរាជ ។

### ខ. តើភារកិច្ចស្របច្បាប់របស់ស្ថាប័នដែលពាក់ព័ន្ធមានអ្វីខ្លះ?

គ.ជ.ប មានសិទ្ធិក្នុងការស៊ើបអង្កេតទៅលើការរំលោភច្បាប់បោះឆ្នោត និងមានភារកិច្ចការពារអ្នកបោះឆ្នោត (ដូចជា ដោយដាក់ពិន័យទៅលើអ្នកបំពាន) សូមមើលមាត្រា៧៦ III CC, មាត្រា១៦ ឃ្លាទី២ និងទី៣ នៃច្បាប់បោះឆ្នោត) ។

រដ្ឋាភិបាលកម្ពុជា មានភារកិច្ចការពារច្បាប់ និងសណ្ដាប់ធ្នាប់សាធារណៈ (មើលមាត្រា ៥២ ឃ្លាទី២ CC ) ។

## ៤. តើពាក្យផ្សេងៗនៅក្នុងមាត្រាសិទ្ធិមនុស្ស មានអត្ថន័យដូចម្ដេច?

អ្នកអាចស្វែងរកពតិមានបន្ថែមលើអត្ថន័យនៃពាក្យថា "សេរីភាពក្នុងការបញ្ចេញមតិ" នៅទំព័រទី៣៩ ហើយនិងពាក្យថា ការបោះឆ្នោត "ដោយសេរី " នៅទំព័រទី៥០ និង៥១ ។ ប្រសិនបើអ្នកមិនដឹងថា ពាក្យថា "សេរីភាពខាងជំនឿសាសនា និងការធ្វើសក្ការៈបូជា" នៅក្នុងមាត្រា៤៣ I II CC មានន័យដូចម្ដេចទេ អ្នកអាចរកឃើញការពណ៌នាកាន់តែពិស្ដារអំពីសេរីភាពនេះនៅក្នុងមាត្រា១៨ I ឃ្លាទី២ ICCPR ។

## ៥. តើមាត្រាសិទ្ធិមនុស្សអាចអនុវត្តចំពោះករណីជាក់លាក់ដែរឬទេ?

សម្ដេចសង្ឃរាជ អាចអះអាងអំពីសេរីភាពក្នុងការបញ្ចេញមតិសម្រាប់ការបញ្ជារបស់ព្រះអង្គ ពីព្រោះព្រះអង្គកំពុងបញ្ចេញមតិជាលាយលក្ខណ៍អក្សរ (មាត្រា១៩ II ICCPR ដែលបញ្ជាក់យ៉ាងច្បាស់ថាគ្រប់រូបភាពទាំងអស់នៃការបញ្ចេញមតិត្រូវបានការពារ គឺមិនមែនមានតែ "ការនិយាយស្ដី"ដោយសេរីតែមួយមុខនោះទេដែលត្រូវបានការពារនោះ) ។

ព្រះអង្គក៏អាចអះអាងអំពីសេរីភាពខាងសាសនា សម្រាប់ការបញ្ជារបស់ព្រះអង្គ ពីព្រោះព្រះអង្គកំពុងអនុវត្ត ក្នុងនាមជាមេដឹកនាំផ្នែកសាសនា ដែលផ្តល់ការណែនាំដល់សមាជិកនៃក្រុមសាសនារបស់ព្រះអង្គ ។ នេះគឺជាផ្នែកមួយនៃការអនុវត្តសេរីភាពខាងសាសនា ( មាត្រា ១៨ III ICCPR ) ។

ព្រះសង្ឃនៅក្រោមបង្គាប់អាចអះអាងអំពីសិទ្ធិក្នុងការបោះឆ្នោត "ដោយសេរី" ។ នេះមានន័យថា មិនមែនមានតែសិទ្ធិបោះឆ្នោតមួយប៉ុណ្ណោះទេដែលត្រូវប្រគេនដល់លោកទៅតាមច្បាប់បោះឆ្នោត សូម្បីតែដំណើការបោះឆ្នោតទាំងមូលដែលរួមបញ្ចូលទាំងការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតផងនោះ ក៏ត្រូវប្រព្រឹត្តទៅ "ដោយសេរី" ផងដែរ។ ដូច្នេះ សិទ្ធិរបស់លោកត្រូវបានប៉ះពាល់រួចទៅហើយ នៅពេលដែលសម្តេចសង្ឃបញ្ជាមិនឱ្យលោកទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត មុននឹងថ្ងៃបោះឆ្នោតខាងមុខមកដល់នោះ ។ អាស្រយ័ដោយពាក្យថា "ដោយសេរី" មានន័យថា មានសេរីភាពរួចពីឥទ្ធិពលមិនសមស្រប ឬខុសច្បាប់នោះ ព្រះសង្ឃអាចអះអាងថា លោកមិនគួររងនូវការគាបសង្កត់ឡើយ ។

ប្រសិនបើសម្តេចសង្ឃរាជ គ្រាន់តែបានបញ្ចេញនូវទស្សនៈផ្ទាល់របស់ព្រះអង្គ ហើយទុកឱ្យព្រះសង្ឃទាំងនោះធ្វើតាមព្រះអង្គដោយសារលោកមានជំនឿលើព្រះអង្គ ឬមិនធ្វើតាមក៏ដោយនោះ គឺវាមិនប៉ះពាល់ដល់សេរីភាពរបស់លោកក្នុងការបោះឆ្នោតឡើយ ។ ពីព្រោះថាប្រភេទនៃឥទ្ធិពលផ្នែកបញ្ញាគឺជាឥទ្ធិពលធម្មតា និងស្របច្បាប់មួយ ។ ប៉ុន្តែការប្រើប្រាស់ការគាបសង្កត់ ដូចជាការចេញបញ្ជាក្នុងរូបភាពជា "ប្រកាស" អាចជាការរំលោភលើសេរីភាពនេះ ។

## ៦. តើមានការដាក់កំហិតអ្វីខ្លះទៅលើសិទ្ធិនេះ?

- សេរីភាពខាងសាសនា : មាត្រា៤៣ II CC គ្រាន់តែការពារសេរីភាពនេះ នៅក្នុងលក្ខខណ្ឌដែលថា វាមិនប៉ះពាល់ដល់"ជំនឿសាសនាដទៃទៀត" ឬក៏រំលោភបំពានទៅលើ "សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ" តែប៉ុណ្ណោះ ។ មាត្រា១៨ III ICCPR រៀបរាប់បន្ថែមអំពី "សុខមាលភាពសាធារណៈ" ក្នុងគោលបំណងដើម្បីដាក់កំហិត ។

សេរីភាពខាងជំនឿសាសនារបស់សម្តេចសង្ឃរាជ អាចត្រូវគេដាក់កំហិតដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ ដែលរួមបញ្ចូលការបោះឆ្នោតដោយសេរីផងដែរ ។ សេរីភាពខាងសាសនាមិនមែនប្រគេនសិទ្ធិដល់ព្រះអង្គក្នុងការគាបសង្កត់ទៅលើអ្នកបោះឆ្នោតដទៃឡើយ ។

- សេរីភាពក្នុងការបោះឆ្នោត : សេរីភាពនេះមិនមានការដាក់កំហិតអ្វីឡើយ ។ វាត្រូវបានការពារទាំងស្រុងដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ( មាត្រា៤៣ I, II និងមាត្រា៧៦ II CC និងមាត្រា២៥ ខ ICCPR ) ។

## ៧. តើមានច្បាប់ពិសេសណាដែលដាក់កំហិតទៅលើសិទ្ធិមនុស្សដែរឬទេ?

ពិតជាមាន ។ សូមមើលនៅក្នុង

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (LEMNA) និង
- ក្រមព្រហ្មទណ្ឌអន្តរកាល

នៅក្នុង LEMNA អ្នកអាចរកឃើញបញ្ញត្តិពិស្តារអំពី ថាតើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គជប) អាចកំណត់យ៉ាងដូចម្តេចអំពីទណ្ឌកម្មចំពោះឥទ្ធិពលមិនសមស្រប និងខុសច្បាប់ទៅលើអ្នកបោះឆ្នោត ។ វាបញ្ញត្តិឱ្យកាន់តែស៊ីជំរៅថែមទៀតនូវការដាក់កំហិតចំពោះបុគ្គលដែលបំពានសិទ្ធិបោះឆ្នោតដោយសេរីរបស់បុគ្គលម្នាក់ទៀត ។

មាត្រា១២៤ LEMNA ជាឧទាហរណ៍បញ្ញត្តិនូវការដាក់កំហិតដែលអាចត្រូវបានកំណត់ដើម្បីការពារសិទ្ធិរបស់អ្នកបោះឆ្នោត ។ បទបញ្ញត្តិនោះគឺ:

មាត្រា១២៤ LEMNA:

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ,និង ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅ ម្ភៃប្រាំលាន (២៥.០០០.០០០) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា និងគណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម :

- *ប្រើ* កម្លាំង ឬអំពើហិង្សា ឬ*បំភិតបំភ័យ* *មិនឱ្យ*ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតទៅ*ចុះឈ្មោះបោះឆ្នោត* ឬ*រារាំងមិនឱ្យចុះឈ្មោះ*ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ...
- ប្រើកម្លាំង ឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ...
- *ប្រើ* កម្លាំង ឬអំពើហិង្សា ឬ*បំភិតបំភ័យ* ប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមាន *ការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្ត* លើការសម្ងាត់នៃការបោះឆ្នោត ...

"សង្ឃប្រកាស"របស់សម្តេចសង្ឃដែលហាមព្រះសង្ឃមិនឱ្យទៅឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត មិនអាចត្រូវបានចាត់ទុកជា"ការប្រើកំលាំង ឬហិង្សា"នោះទេ ប៉ុន្តែ វាជា"ការគំរាមកំហែង" ដែលធ្វើឱ្យព្រះសង្ឃក្នុងានាមជាប្រជាពលរដ្ឋ និងជាអ្នកបោះឆ្នោត "ញញើត"ក្នុងការចុះឈ្មោះបោះឆ្នោតតាមបញ្ញត្តិមាត្រា១២៤ LEMNA ព្រោះថាព្រះសង្ឃអាចមានការភ័យខ្លាចក្នុងការធ្វើអ្វីមួយខុស និងអ្វីដែលបានហាមឃាត់ បើសិនណាការចុះឈ្មោះនោះផ្ទុយនឹងបញ្ជារបស់សម្តេចសង្ឃ ។ *(ផ្ទុយមកវិញ គេអាចនិយាយបានថា ការគំរាមកំហែងគ្រាន់តែជាអំពើមួយដែលធ្វើឱ្យមានការភ័យខ្លាច ឬការព្រួយបារម្ភ ឬការរន្ធត់ ឬមានអារម្មណ៍ប្រហាក់ប្រហែលនេះតែប៉ុណ្ណោះ ។)*

ដូចដែលការពិតជាក់ស្តែងត្រូវបានបង្ហាញថា វាអាចចាត់ទុកផងដែរជាអំពើមួយ "ឃាឃាំង" ដល់ការចុះឈ្មោះបោះឆ្នោតរបស់ព្រះសង្ឃ ។ នៅពេលដែល"សង្ឃប្រកាស" ត្រូវបានបិទផ្សាយនៅឯមណ្ឌលចុះឈ្មោះបោះឆ្នោត នៅក្នុងករណីជាច្រើន ព្រះសង្ឃរារែកពុំហ៊ានទៅចុះឈ្មោះ ឬមន្ត្រីចុះឈ្មោះមិនព្រមចុះឈ្មោះឱ្យព្រះសង្ឃដោយសំអាងលើសង្ឃប្រកាសនោះ ។ *(ផ្ទុយមកវិញ គេអាចនិយាយបានថា អំពើរារាំងដល់ការចុះឈ្មោះត្រូវបានប្រព្រឹត្តដោយមន្ត្រីចុះឈ្មោះដែលជាអ្នកមានឥទ្ធិពលលើការចុះឈ្មោះតែប៉ុណ្ណោះ ។ ប៉ុន្តែ ដូចដែលមាត្រា១២៤ LEMNA មិនបានចង្អុលឱ្យចំនរណាម្នាក់ ហើយនិងមិនចំពោះមន្ត្រីចុះឈ្មោះដូចដែលមានចែងក្នុងមាត្រា១២២ LEMNA នោះដែរ ដូចនេះការបកស្រាយនេះដូចជាមិនត្រឹមត្រូវទេ ។)*

នៅទីបញ្ចប់ "សង្ឃប្រកាស" អាចជាការសំឡុតអ្នកបោះឆ្នោត (ព្រះសង្ឃ) ឱ្យភាន់ច្រឡំអំពីសិទ្ធិរបស់ព្រះអង្គ ធ្វើឱ្យព្រះសង្ឃទាំងនោះពិបាកសំរេចព្រះទ័យថា គួរ ឬមិនគួរគោរពតាមសង្ឃប្រកាស ហើយទៅបោះឆ្នោត ។ វាអាចជាអំពើ "គំរាមកំហែង" ដល់អ្នកបោះឆ្នោត ដើម្បី "ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តដល់ការបោះឆ្នោត" ព្រោះថាព្រះសង្ឃត្រូវបានសាធារណជនចាត់ទុកថាជាគំរូដ៏ល្អមួយនៃការរស់នៅដោយសុចរិត ហើយព្រះសង្ឃគឺជាអ្នកដែលទទួលបានការអប់រំជ្រៅជ្រះ បែរជាមិនបានទៅបោះឆ្នោត អំពើនេះធ្វើឱ្យប៉ះពាល់ដល់ការយល់ដឹងរបស់សាធារណជនអំពីតំលៃ

ជាវិធីអហិង្សាក្នុងការបញ្ចេញឆន្ទៈនយោបាយនៃការបោះឆ្នោត ។ *(ជាការបកស្រាយផ្ទុយមកវិញ គេអាចនិយាយថា ការគំរាមកំហែងផ្តល់នូវគុណវិបត្តិភ្លាមៗ និងធ្ងន់ធ្ងរនៅពេលអនាគត ដែលធ្វើឱ្យបុគ្គលដែលត្រូវគេគំរាមកំហែងមានការព្រួយបារម្ភ ។)*

ដោយសារតែការបញ្ចេញឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោត នឹងត្រូវតែទទួលបានការការពារ វាត្រឹមត្រូវណាស់ក្នុងការអះអាងថា ការជះឥទ្ធិពល និងការជ្រៀតជ្រែកក្នុងរូបភាពណាមួយក៏ដោយ ត្រូវបានចាត់ទុកថាជាការបំពានលើសិទ្ធិបោះឆ្នោត ដូចនេះវាពុំចាំបាច់គិតពីការរន្ធត់ ការភ័យខ្លាច ឬការព្រួយបារម្ភរបស់អ្នកគ្រោះនោះទេ ប៉ុន្តែ ឥទ្ធិពលមិនសមស្របដែលបង្កដោយការសំឡុត ឬការបង្ខិតបង្ខំ ដូចជាបញ្ជារបស់ថ្នាក់លើដែលប្រើសមត្ថកិច្ច និងអំណាចរបស់គាត់ ជាអំពើផ្ទុយច្បាប់រួចទៅហើយ ។

បទបញ្ញត្តិដែលច្បាស់បំផុត គឺមាត្រា៦៤ នៃក្រមព្រហ្មទណ្ឌអន្តរកាល ដែលការពារយ៉ាងជាក់លាក់ចំពោះ "ការអនុវត្តនីដោយសេរីនូវសិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោតម្នាក់" ប្រឆាំងនឹង "ការបង្ខិតបង្ខំ និងការជ្រៀតជ្រែកក្នុងរូបភាពណាមួយក៏ដោយ" មិនមែនត្រឹមតែការគំរាមកំហែងប៉ុណ្ណោះទេ ប៉ុន្តែរួមទាំង "ការប្រព្រឹត្តខុសច្បាប់" ផងដែរ ។

ជាឧទាហរណ៍នៃការប្រព្រឹត្តខុសច្បាប់អាចមើលឃើញថា សម្តេចសង្ឃប្រើប្រាស់អំណាច និងឥទ្ធិពលរបស់គាត់ដើម្បីបញ្ជាផ្ទាល់ទៅដល់អ្នកក្រោមបង្គាប់ ដែលពឹងផ្អែកទៅលើសម្តេចសង្ឃ និងការដឹកនាំរបស់លោក មិនឱ្យទៅបោះឆ្នោត ។ ហេតុដូច្នេះហើយ នេះជាអំពើដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ និង LEMNA ដែលការពិតចង់បានការអនុវត្តនីដោយសេរីនៃឆន្ទៈរបស់អ្នកបោះឆ្នោត ។

ទោះបីជាយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាត្រូវបានចាត់ទុកជាសាសនារបស់ជាតិដោយរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា៤៣ III CC) ហើយមិនបានផ្តល់អំណាចឱ្យសម្តេចសង្ឃទៅជ្រៀតជ្រែកបញ្ហានយោបាយ និងបញ្ហាសំខាន់ៗរបស់រដ្ឋដូចជាការបោះឆ្នោតជាដើមនោះទេ ពីព្រោះថា មាត្រា៤៣ II CC ចែងយ៉ាងច្បាស់ថា ការប្រើប្រាស់សេរីភាពខាងសាសនាមិនត្រូវរំលោភបំពានលើសណ្តាប់ធ្នាប់សាធារណៈដែលក្នុងនោះរួមមានការបោះឆ្នោតដោយសេរីផងដែរ ។ ដូច្នេះសម្តេចសង្ឃប្រព្រឹត្តនេះ "មិនត្រឹមត្រូវតាមច្បាប់" ទេ ប្រសិនបើគាត់នៅតែមិនទៅស្ងៀម និងអព្យាក្រិត្យ ហើយព្យាយាមយ៉ាងសកម្មក្នុងការរារាំងមិនឱ្យព្រះសង្ឃទៅបោះឆ្នោតនោះ ។ មិនទៅបោះឆ្នោតពុំមែនជាអំពើអព្យាក្រឹត្យទេ ប៉ុន្តែជាទំរង់នៃការបញ្ចេញនូវឆន្ទៈនយោបាយមួយ ។

## ៨. តើការដាក់កំហិតដែលបានកំណត់នោះ មានលក្ខណៈសមាមាត្រឬក៏ខ្លាំងពេក? (គោលការណ៍នៃភាពសមាមាត្រ)

LEMNA ផ្តល់ឱ្យ គជប នូវវិធានការណ៍ខុសៗគ្នាដើម្បីតបត (មាត្រា ១៦ ចំនុច១, ១៦, ២៤ និងចំនុច២៨ និងមាត្រា១២២ ចំនុច៤ និងមាទ្រា ១២៤ LEMNA ) ។ គជប ត្រូវទទួលខុសត្រូវក្នុងការទប់ស្កាត់ដល់ភាពមិនប្រក្រតីដែលកើតមានក្នុងការបោះឆ្នោត និងចំពោះការត្រួតពិនត្យឡើងអំពីភាពស្របច្បាប់នៃការបោះឆ្នោត។ ដូច្នេះហើយ គជប មានភារកិច្ចពិនិត្យមើលភាពស្របច្បាប់នៃសង្ឃប្រកាសរបស់សម្តេចសង្ឃ ។

ដំបូង គជប អាចនិយាយជាមួយនឹងសម្តេចសង្ឃ និងប្រាប់លោកអំពីគោលការណ៍នៃការបោះឆ្នោតដោយសេរី ។ ករណីនេះ អាចជាវិធានការណ៍ស្រាលបំផុត ។

គ. ជ. ប អាចបន្ត

- ចេញជាការប្រមានមួយ ឬ
- ណែនាំឱ្យព្រះអង្គដកបទបញ្ជារបស់ព្រះអង្គចេញ ឬ
- ដាក់ពិន័យ (មាត្រា១២៤ LEMNA) ឬ
- ដាក់ពាក្យបណ្តឹងដល់ព្រះរាជអាជ្ញាឱ្យដាក់ទោសព្រហ្មទណ្ឌ (មាត្រា៦៤ នៃក្រមព្រហ្មទណ្ឌអន្តរកាល វិធានការខ្លាំងជាងគេ) ។ តុលាការព្រហ្មទណ្ឌ អាចនឹងវិនិច្ឆ័យទោស ប្រសិនណាច្បាប់នេះពិតជាត្រូវបានបំពានមែន ។ វាមិនចាំបាច់ធ្វើបណ្តឹងប្រឆាំងនឹងសម្តេចសង្ឃ

## សំនួរសិក្សាទី ១៤

ក. សូមរៀបរាប់ពីបទបញ្ញត្តិជាតិ និង អន្តរជាតិ (ចំនួនមាត្រា) ដែលការពារសេរីភាពក្នុងការរួមប្រជុំ ។

បទបញ្ញត្តិអន្តរជាតិ:

- មាត្រា២០ ចំនុចទី១ UDHR (សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស)
- មាត្រា២១ ឃ្លាទី១ ICCPR (កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)
- មាត្រា៥ ឃ (៩) CERD (អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់នូវការរើសអើងពូជសាសន៍)
  (មាត្រា១៥ I CRC (អនុសញ្ញាស្តីពីសិទ្ធិកុមារ) ជាការការពារពិសេសសំរាប់សេរីភាពរួមប្រជុំរបស់កុមារ)

បទបញ្ញត្តិជាតិ

- មាត្រា៤១ I នៃរដ្ឋធម្មនុញ្ញកម្ពុជា
- មាត្រា១ ឃ្លាទី១ នៃច្បាប់ស្តីពីបាតុកម្ម

ខ. តើអ្វីខ្លះជាការដាក់កំហិតលើសេរីភាពក្នុងការរួមប្រជុំ?

- មាត្រា៤១ **ឃ្លាទី២** នៃរដ្ឋធម្មនុញ្ញកម្ពុជា:

"... ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិបានឡើយ..."

- មាត្រា **២១ ឃ្លាទី២** ICCPR:

"... គ្មានការដាក់កំហិតណាមួយអាចធ្វើទៅបានលើការអនុវត្តសិទ្ធិនេះបាន ជាងការជំរុញឱ្យស្របច្បាប់ និងភាពចាំបាច់នៃសង្គមប្រជាធិបតេយ្យ ក្នុងប្រយោជន៍នៃសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការពារសុខមាលភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពអ្នកដទៃ ។"

ហេតុដូច្នេះ ការដាក់កំហិតលើសេរីភាពរួមប្រជុំអាចជា:

- សិទ្ធិរបស់អ្នកដទៃ (ICCPR "សិទ្ធិ និងសេរីភាពរបស់អ្នកដទៃ")
- ទំនៀមទម្លាប់ល្អរបស់សង្គម (ICCPR "សីលធម៌")
- ច្បាប់ និង សណ្តាប់ធ្នាប់សាធារណៈ (ICCPR "សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ")
- សន្តិសុខជាតិ (ICCPR "សន្តិសុខជាតិ")
- សុខមាលភាពសាធារណៈ (ICCPR)

ក្នុងន័យស៊ីជំរៅៈ

- សិទ្ធិអ្នកដទៃៈ សិទ្ធិមនុស្សរបស់អ្នកដទៃ
- ទំនៀមទម្លាប់ល្អរបស់សង្គមៈ នេះជាពាក្យច្បាប់ដែលមានន័យទូលាយណាស់ និងអាស្រ័យតែទៅលើសង្គមផ្ទាល់ដែលជាអ្នកកំណត់អំពីទំនៀមទម្លាប់ទាំងនោះ ។ អ្នកធ្វើច្បាប់ដែលជាអ្នកតំណាងសង្គម ជាអ្នកកំណត់និយមន័យពាក្យនៅក្នុងអត្ថបទច្បាប់ (ដូចជាមាត្រា១៤ នៃច្បាប់ស្តីពីសារពត៌មាន) ។ ឧទាហរណ៍ស្តីពី "ទំនៀមទម្លាប់ល្អរបស់សង្គមខ្មែរ" អាចថាជាការគោរពចាស់ទុំ (មាត្រា៤៧ II CC) ឬការគោរពព្រះមហាក្សត្រកម្ពុជា "ដែលមិនអាចរំលោភបំពាន"បាន (មាត្រា៧ III CC)។
- ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈៈ ច្បាប់ទាំងឡាយដែលការពារសិទ្ធិអ្នកដទៃ
- សន្តិសុខជាតិៈ "សន្តិសុខជាតិ" មិនមែនបានន័យថា គ្រប់ផលប្រយោជន៍សន្តិសុខរបស់រដ្ឋាភិបាលនោះទេ ប៉ុន្តែវាជាការគំរាមកំហែងដល់អាយុជីវិត និងសន្តិសុខទាំងមូលរបស់ជាតិ (ឧទាហរណ៍ ប្រទេសផ្សេងធ្វើការវាយប្រហារដោយយោធា មកលើប្រទេសកម្ពុជា ឬញុះញង់ឱ្យមានហិង្សាទំលាក់រដ្ឋាភិបាល)
- សុខមាលភាពសាធារណៈៈ សុខភាពរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដូចជា ជំងឺ SARS ឬ DENGUE អាចត្រូវចាត់ថាការគំរាមកំហែងដល់សុខមាលភាពសាធារណៈ

គ. នៅខែកុម្ភៈ ឆ្នាំ២០០៣ អង្គភាពនគរបាល អង្គភាពកងរាជអាវុធហត្ថ និងការបិទផ្លូវ បានបោះទីតាំងនៅតាមបណ្តាផ្លូវសំខាន់ៗជាច្រើនក្នុងក្រុងភ្នំពេញ ដើម្បីរារាំងមិនឱ្យក្រុមបាតុករចូលក្នុងក្រុង ។ ក្រុមបាតុករដែលមកពីខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង និងកំពង់ស្ពឺ បានជឿតាមការអំពាវរបស់ "ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា" ដែលជាសហគមន៍មួយមាន ៥ក្រុម ឱ្យមកជួបជុំគ្នានៅក្រុងភ្នំពេញ ដើម្បីសំរេចធ្វើបាតុកម្មសុំឱ្យមានការដោះលែងនិស្សិតទាំងឡាយ និងអ្នកកាសែតដែលត្រូវចាប់ខ្លួនដោយសារកុបកម្មប្រឆាំងនឹងថៃនៅខែថ្ងៃទី២៩ មករា ។ សមាជិករបស់ក្រុមប្រឹក្សានៃអ្នកឃ្លាំមើល មុននេះបន្តិចបានអំពាវនាវសុំឱ្យមានការលាលែងតំណែងរបស់សម្តេច ហ៊ុន សែន បានលុបចោលការជួបប្រជុំនៅក្បែររដ្ឋសភា ដោយសារវត្តមានរបស់ក្មេងវត្តដែលជាក្រុមគាំទ្រសម្តេច ហ៊ុន សែន (ដកស្រង់ចេញពីកាសែត The Cambodia Daily ចុះថ្ងៃទី១១ កុម្ភៈ ២០០៣)

តើវិធានការដែលប៉ូលីសបានចាត់ឡើងនៅក្នុងអត្ថបទទី១ (ប៉ូលីសៈ អ្នកតវ៉ាត្រូវចេញឱ្យឆ្ងាយពីទីក្រុង) ស្របច្បាប់ ឬមិនស្របច្បាប់?

វាមិនស្របច្បាប់ទេ ។

មូលហេតុៈ

កងកម្លាំងប៉ូលីសបានរារាំងមនុស្សដែលប្រកបដោយសន្តិវិធី និងគ្មានអាវុធ ពីការចូលទៅដល់កន្លែងធ្វើបាតុកម្ម ទោះបីជា គ្មានការបញ្ជាក់ដែលមានមូលដ្ឋានលើអង្គហេតុច្បាស់លាស់ និងជាក់លាក់ដែលថាការប្រមូលផ្តុំរបស់ពួកគេអាចនាំឱ្យមានអំពើហិង្សាក៏ដោយ ។ ទោះជាបាតុកម្មតបត (ដែលធ្វើឡើងដោយ "សមាគមក្មេងវត្ត) និងអំពើហិង្សាមានការប៉ះទង្គិចគ្នារវាងក្រុមអ្នកគាំទ្រសម្តេចហ៊ុន សែន និងក្រុមប្រឆាំងនឹងសម្តេច ហ៊ុន សែន ក៏មិនបង្ហាញថាជាវិធានការណ៍ខ្លាំងក្លាទេ ។

ប៉ុន្តែ ទង្វើផ្ទុយពីនេះគឺជាការពិត: អាជ្ញាធរជាប់កាតព្វកិច្ចក្នុងការបង្កើតកាលៈទេសៈណាដែលសិទ្ធិជាមូលដ្ឋាននៃសេរីភាពរួមប្រជុំ អាចត្រូវបានអនុវត្តដោយគ្មានការរំខាន ។

ឧទាហរណ៍: ការអនុញ្ញាតឱ្យប្រជាពលរដ្ឋទៅដល់កន្លែងធ្វើបាតុកម្ម និង ការពារពួកគេ និងបាតុកម្មរបស់ពួកគេប្រឆាំងនឹងអំពើហិង្សារបស់មនុស្សផ្សេងទៀត ដោយធ្វើការបំបែកបាតុកម្មទាំងពីរក្រុមនោះចេញពីគ្នា ។

វាមិនទាន់គ្រប់គ្រាន់ទេក្នុងការដែលថាអាជ្ញាធរគ្រាន់តែ "គិត" (សូមមើលមាត្រា៣ ឃ្លាទី២ នៃច្បាប់ស្តីពីបាតុកម្ម) ថា បាតុកម្មនឹងនាំមកនូវអំពើហិង្សា បើត្រឹមតែជាការសន្មត់តាមទ្រឹស្តីនោះ **មិនអាច**បង្ហាញថា ការកាត់បន្ថយនៃសេរីភាពក្នុងការរួមប្រជុំធ្លាក់ដល់សូន្យនោះទេ ។

ឃ. នៅថ្ងៃទី៥ ធ្នូ ២០០២ បាតុកម្មមួយដែលមានមនុស្សប្រហែល ១៧៥នាក់ ដែលសង្ឃឹមថានឹងមានការពិភាក្សាអំពីផែនការកាប់ឈើជាមួយក្រុមហ៊ុនកាប់ឈើ និងនាយកដ្ឋានរុក្ខា ត្រូវបំបែកឱ្យរត់ខ្ចាត់ខ្ចាយនៅខាងក្រៅនាយកដ្ឋានរុក្ខាដោយកំលាំងប៉ូលីស និងកងរាជអាវុធហត្ថ ដែលប្រើដំបងអគ្គិសនីវាយ ។ យោងតាមអ្នកតាមដានការកាប់ព្រៃឈើ "អង្គការសាក្សីពិភពលោក" មានមនុស្សចំនួន ១២នាក់ ត្រូវរងរបួស និងបុរសម្នាក់អាយុ ២៩ឆ្នាំ បានស្លាប់បន្ទាប់ពីរយៈពេលជាច្រើនម៉ោងនៃការបំបែកការប្រមូលផ្តុំនោះ ប៉ុន្តែមូលហេតុដែលថាការស្លាប់ដោយសារតែជំងឺគាំងបេះដូងនោះនៅមិនទាន់ច្បាស់នៅឡើយទេ ។ មន្ត្រីប៉ូលីសបានបដិសេធចំពោះការដែលថាមន្ត្រីរបស់ពួក គេវាយក្រុមបាតុករ ប៉ុន្តែអះអាងថា ក្រុមបាតុករបានបិទរបងនាយកដ្ឋានរុក្ខា ហើយមន្ត្រីនគរបាលម្នាក់បានអំពាវនាវឱ្យក្រុមបាតុករចេញ (ដកស្រង់ចេញពីកាសែត ចេញថ្ងៃទី៧ ធ្នូ ២០០២) ។

សូមប្រើ "បញ្ជីផ្ទៀងផ្ទាត់ដើម្បីដោះស្រាយករណីរឿងសិទ្ធិមនុស្ស" នៅទំព័រទី៣៣ និងឆ្លើយសំនួរទាំងអស់មួយជំហានម្តងៗ!

## បញ្ជីផ្ទៀងផ្ទាត់ដើម្បីដោះស្រាយករណីសិទ្ធិមនុស្ស

### ១. តើមានមនុស្ស និងស្ថាប័នណាខ្លះដែលពាក់ព័ន្ធនៅក្នុងវិវាទ?

- អ្នកភូមិដែលធ្វើបាតុកម្មនៅខាងមុខនាយកដ្ឋានរុក្ខា (DoF) (ក)
- បុគ្គលិកនៃនាយកដ្ឋានរុក្ខា (ខ)
- ប៉ូលីស និង រាជអាវុធហត្ថ (គ)
- អង្គការក្រៅរដ្ឋាភិបាល ដូចជា "អង្គការសាក្សីពិភពលោក" (មិនពាក់ព័ន្ធដោយផ្ទាល់នឹងជម្លោះទេ) (ឃ)



## ២. តើអ្វីខ្លះជាទំនាស់ផលប្រយោជន៍របស់មនុស្ស និងស្ថាប័នទាំងនោះ ហើយតើពួកគេមានទំនាក់ទំនងគ្នាដូចម្តេច?




## ៣. សិទ្ធិ និងភារកិច្ចៈ

### ក. តើមានសិទ្ធិអ្វីខ្លះដែលត្រូវប៉ះពាល់?

អ្នកភូមិ

ក

- សិទ្ធិរស់រានមានជីវិត មាត្រា៣២ I CC
- សេរីភាពក្នុងការបញ្ចេញមតិ មាត្រា៤១ I CC
- សេរីភាពក្នុងការរួមប្រជុំ មាត្រា៤១ I CC

បុគ្គលិកនៃនាយកដ្ឋានរុក្ខា

ខ

- សេរីភាពក្នុងការដើរហើរ មាត្រា៣២ I CC

NGO

ឃ

សេរីភាពក្នុងការបញ្ចេញមតិ មាត្រា៤១ I CC
សេរីភាពក្នុងការរួមប្រជុំ មាត្រា៤១ I CC
សេរីភាពចូលរួមជាសមាគម មាត្រា៤២ I CC

### ខ. តើភារកិច្ចស្របច្បាប់របស់ស្ថាប័នពាក់ព័ន្ធមានអ្វីខ្លះ?

រដ្ឋាភិបាលកម្ពុជាមានភារកិច្ច ការពារច្បាប់ និងបទបញ្ជា មាត្រា៥២ ឃ្លាទី២ CC ។ ដើម្បីបំពេញភារកិច្ចនេះ រដ្ឋាភិបាលបានបង្កើតឱ្យមានប៉ូលីស ។

## ៤. តើអត្ថន័យនៃពាក្យផ្សេងៗគ្នានៅក្នុងសិទ្ធិមនុស្សមានអ្វីខ្លះ?

- សិទ្ធិរស់រានមានជីវិត: ដើម្បីការពារខ្លួនឯងប្រឆាំងនឹងការគំរាមកំហែងលើបូរណភាពរាងកាយ
- សេរីភាពបញ្ចេញមតិ: លំហូរ និងផ្លាស់ប្តូរពត៌មានដោយសេរី ទទួលបាននូវពត៌មានគ្រប់ប្រភេទពីប្រព័ន្ធផ្សព្វផ្សាយ ( សៀវភៅ កាសែត អ៊ិនធើណិត វិទ្យុ ទូរទស្សន៍ ភាពយន្ត ។ល។)
- សេរីភាពជួបប្រជុំ: ដើម្បីប្រមូលផ្តុំគ្នាដោយសន្តិវិធីជាមួយមនុស្សផ្សេងទៀតជាសាធារណៈ ឬជាឯកជនដោយមានចេតនារួមដើម្បីបញ្ចេញមតិយោបល់ ពត៌មាន ឬគំនិត
- សេរីភាពដើរហើរ: ដើម្បីផ្លាស់ទីទៅកន្លែងណាដែលអ្នកចង់ទៅ
- សេរីភាពសមាគម: ដើម្បីរៀបចំនៅក្នុងរចនាសម្ព័ន្ធជាក់លាក់ និងស្ថិតស្ថេរ ដើម្បីស្វែងរកប្រយោជន៍រួម

## ៥. តើមាត្រាច្បាប់សិទ្ធិមនុស្សណាខ្លះអនុវត្តទៅលើករណីជាក់ស្តែងនេះ?

- អ្នកភូមិ: ពួកគេចង់រស់ ព្រោះពួកគេរស់នៅដោយទាញផលពីព្រៃឈើទាំងនោះ ។ ពួកគេចង់ថែរក្សាធនធានសំរាប់ការចិញ្ចឹមជីវិត ។ ដើម្បីគូសបញ្ជាក់អំពីផលប្រយោជន៍ពួកគេបានមកជួបជុំនៅខាងមុខនាយកដ្ឋានរុក្ខា និងចង់ពិភាក្សាអំពីផែនការកាប់ឈើដែលអាចបំផ្លាញមូលដ្ឋាននៃការរស់នៅរបស់ពួកគេ ។
  **បាទ/ចាស** មាត្រា៣២ I និងមាត្រា៤១ I CC អនុវត្តចំពោះករណីនេះ ។
- បុគ្គលិកនាយកដ្ឋានរុក្ខា: ពួកគេចង់ចូល និងចេញពីនាយកដ្ឋានដោយសេរី នៅពេលណាដែលពួកគេចង់ ។
  **បាទ/ចាស** មាត្រា៣២ I CC អនុវត្តចំពោះករណីនេះ ។

## ៦. តើមានការដាក់កំហិតអ្វីខ្លះទៅលើសិទ្ធិដែលពាក់ព័ន្ធ?

- ការដាក់កំហិតលើសិទ្ធិរបស់អ្នកភូមិ:
  - ការដាក់កំហិតលើសិទ្ធិរស់រានមានជីវិត: មាត្រា៣១ II ២ CC:
    "សិទ្ធិ និង សេរីភាព អ្នកដទៃ"
  - ការដាក់កំហិតលើសេរីភាពក្នុងការបញ្ចេញមតិ: មាត្រា៤១ I ២ CC:
    "សិទ្ធិរបស់អ្នកដទៃ"
    "ទំនៀមទំលាប់ល្អរបស់សង្គម"
    "ច្បាប់ និង បទបញ្ជាសាធារណៈ"
    "សន្តិសុខជាតិ"
  - ការដាក់កំហិតលើសេរីភាពជួបប្រជុំ: មាត្រា៤១ I ២ CC:
    ដូចគ្នានឹងសេរីភាពនៃការបញ្ចេញមតិដែរ

- ការដាក់កំហិតលើសិទ្ធិរបស់បុគ្គលិកនាយកដ្ឋានរុក្ខា:
  - ការដាក់កំហិតលើសេរីភាពក្នុងការដើរហើរ មាត្រា៣១ II ២ CC :
    "សិទ្ធិ និងសេរីភាពអ្នកដទៃ"

## ៧. តើមានច្បាប់ពិសេសណាដែលចែងដាក់កំហិតលើសិទ្ធិមនុស្សដែរឬទេ ?

អ្នកភូមិ:

សិទ្ធិរស់រានមានជីវិត: ច្បាប់ភូមិបាល ច្បាប់នេសាទ ច្បាប់ព្រៃឈើ ច្បាប់ព្រហ្មទណ្ឌ

សេរីភាពបញ្ចេញមតិ: ច្បាប់សារពត៌មាន ច្បាប់ព្រហ្មទណ្ឌ

សេរីភាពជួបប្រជុំ: ច្បាប់ស្តីពីបាតុកម្ម ច្បាប់ស្តីពីចរាចរផ្លូវគោក ច្បាប់ព្រហ្មទណ្ឌ

បុគ្គលិករបស់នាយកដ្ឋានរុក្ខា:

សេរីភាពក្នុងការដើរហើរ: ច្បាប់ស្តីពីចរាចរ ច្បាប់ព្រហ្មទណ្ឌ

## ៨. តើការដាក់កំហិតដែលដាក់ឱ្យអនុវត្តនោះមានលក្ខណៈសមាមាត្រ ឬខ្លាំងជ្រុលហួសហេតុ? (គោលការណ៍នៃភាពសមាមាត្រ)

ឬមួយអ្នកអាចសួរបានដែរថា: តើគួរមានវិធានការណ៍អ្វីដែលនាំមកនូវជោគជ័យធំបំផុត និងមានការខូចខាតតិចតួច លើសិទ្ធិដែលពាក់ព័ន្ធ?

### វិធានការពីខ្សោយទៅខ្លាំង:

ក. ប៉ូលីស - ដោយប្រើឧបករណ៍បំពងសំលេង - អាចដាក់លក្ខខណ្ឌលើអ្នកភូមិដូចជា: "សូមចាកចេញពីផ្លូវចូលនាយកដ្ឋានរុក្ខា និងសូមថយក្រោយ២០ម៉ែត្រ"

ខ. ប្រសិនបើក្រុមបាតុករមិនធ្វើតាមការបញ្ជានោះទេ ប៉ូលីសអាចរំលឹកលក្ខខណ្ឌដដែលម្តងទៀត និងបន្ថែមជាមួយនឹងការព្រមានថា: "ប្រសិនបើអ្នកទាំងអស់គ្នាមិនថយក្រោយដើម្បីបើកផ្លូវចេញចូលនាយកដ្ឋានទេ ប៉ូលីសនឹងប្រើកំលាំងបណ្តេញមនុស្សពាក់ព័ន្ធទាំងអស់ឱ្យទៅផ្លូវម្ខាងទៀត !

គ. ប្រសិនបើបាតុករខ្លះនៅតែប្រឆាំងនឹងបញ្ជាលើកទី២នេះទៀត ប៉ូលីសអាចប្រើកំលាំងបាយចាប់ និងបណ្តេញមនុស្សពាក់ព័ន្ធទាំងនោះទៅផ្លូវម្ខាង ។ កំលាំងបាយរបស់ប៉ូលីសនេះមានន័យថា ការចាប់មនុស្សដែលប្រឆាំងទៅដាក់នៅផ្លូវម្ខាង និងដោយមិនវាយ និងបាញ់ពួកគេទេ !

ឃ. ប្រសិនបើបាតុករប្រើហិង្សាខណៈពេលដែលប៉ូលីសកំពុងបណ្តេញពួកគេចេញនោះ ប៉ូលីសអាចឃាត់ខ្លួនពួកគេជាបណ្តោះអាសន្នបាន ។

នៅក្នុងករណីរបស់យើងនេះ ក្រុមបាតុករបានប្រមូលផ្តុំគ្នាដោយសន្តិវិធី និងគ្មានអាវុធ ។ គ្មានការបញ្ជាក់ដែលមានមូលដ្ឋានលើអង្គហេតុណាមួយថា បាតុកម្មរបស់ពួកគេអាចនឹងមានហិង្សា ដែលមានន័យថា ជាការគំរាមកំហែងដោយជាក់ស្តែង និងដោយផ្ទាល់ទៅលើសន្តិសុខរបស់ពលរដ្ឋដទៃទៀតឡើយ ។ មានតែទង្វើមួយគត់ដែលពួកគេបានធ្វើ គឺបានបិទផ្លូវចេញចូលនាយកដ្ឋានរុក្ខា ។ ប៉ុន្តែបញ្ហានេះអាចដោះស្រាយបានដោយងាយស្រួលតាមវិធានការដែលបានពិពណ៌នាពី ក ដល់ ឃ ។ ដូច្នេះកំលាំងប៉ូលីសបានបំពានលើសិទ្ធិរបស់ពួកគេដែលមានចែងក្នុងមាត្រា៦ I នៃច្បាប់ស្តីពីបាតុកម្មក្នុងការចាត់"វិធានការដែលសមស្របបំផុត"ដើម្បីបញ្ឈប់បាតុកម្ម ។ ពួកគេបានប្រើដំបង អគ្គិសនីដោយងាយៗ ដើម្បីវាយទៅលើក្រុមបាតុករសន្តិវិធី និងសូម្បីតែវាអាចជាលទ្ធភាពមួយបណ្តាលបុរសវ័យក្មេងអាយុ ២៩ឆ្នាំ មានជំងឺគាំងបេះដូងស្លាប់ដោយសារកំលាំងមិនចាំបាច់របស់ប៉ូលីស ។

ហេតុដូច្នេះ សកម្មភាពរបស់ប៉ូលីសគឺមិនស្របច្បាប់ទេ ។

## សំនួរសិក្សាទី ១៥

នៅខែមករា ២០០៣ ក្រុមបាតុករខ្មែរប្រើហិង្សាបានវាយប្រហារទៅលើហាងទំនិញ និងអាគាររបស់ជនជាតិថៃ និងបណ្តេញជនជាតិថៃ ។ ដែលក្នុងករណីខ្លះពួកគេទទួលរងការឈឺចាប់នៅពេលដែលលោតចេញតាមបង្អួចចុះមកដី ។

ប៉ូលីសមិនបានបញ្ឈប់ក្រុមបាតុករទេ ។

ក. តើសិទ្ធិជាមូលដ្ឋានរបស់ភាគីជម្លោះដែលពាក់ព័ន្ធមានអ្វីខ្លះ?

បាតុករ:
សិទ្ធិក្នុងការនិយាយស្តីដោយសេរី មាត្រា៤១ CC
សិទ្ធិរួមប្រជុំ មាត្រា៤១ CC

ជនជាតិថៃ:
សិទ្ធិរស់រានមានជីវិត មាត្រា៣២ CC
សិទ្ធិលើកម្មសិទ្ធិ មាត្រា ៤៤ CC
សិទ្ធិស្មើភាពគ្នា មាត្រា ៣១ CC

ខ. តើអ្វីខ្លះជាមូលហេតុនៃអំពើហិង្សានេះ?

- មានអារម្មណ៍ចំពោះចំណុចខ្សោយ និង ការមិនគោរពរបស់ជនជាតិថៃ
- ត្រូវការអារម្មណ៍យ៉ាងខ្លាំង និង ខ្ពស់ដោយធ្វើការវាយប្រហារលើជនជាតិថៃ
- មិនគោរពជនជាតិថៃ ដែលថាជាមនុស្សស្អប់ជាតិសាសន៍ និងជាតិ
- គ្មានការដាក់ទោសចំពោះក្រុមបាតុករដែលប្រើហិង្សា

គ. តើមានបទបញ្ញាច្បាប់អ្វីខ្លះដែលហាមឃាត់ការផ្សព្វផ្សាយអំពីការស្អប់ជាតិសាសនន៍នៅប្រទេសកម្ពុជា?

ច្បាប់សារពត៌មាន:
មាត្រា៦ ចំនុចទី៦: អ្នកកាសែតត្រូវជៀសវាងការផ្សព្វផ្សាយពត៌មានដែលញុះញង់ឱ្យមានការរើសអើងជាតិសាសន៍
មាត្រា១១: សារពត៌មាន មិនត្រូវបោះពុម្ពផ្សាយអំពីអ្វីដែលអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយការញុះញង់ផ្ទាល់ ឬនាំឱ្យមនុស្សច្រើននាក់ប្រព្រឹត្តអំពើហិង្សានោះទេ ។

ច្បាប់ព្រហ្មទណ្ឌ:
មាត្រា៦១ I: ការបង្កឱ្យមានការស្អប់ជាតិ សាសនា ឬ ជាតិសាសន៍ ដែលបង្កើតការញុះញង់នឱ្យមានការរើសអើង

ICCPR: ច្បាប់ត្រូវតែការពារប្រឆាំងនូវរាល់ការរើសអើង

កតិកាសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ចោលនូវការរើសអើងពូជសាសន៍គ្រប់ប្រភេទ:
បណ្តាប្រទេសហត្ថលេខីទាំងអស់ សន្យាដាក់ទោសចំពោះការផ្សព្វផ្សាយគ្រប់គំនិតនៃការរើសអើងគ្រប់ប្រភេទ ។